

■ លោកអភិបាល អូលីវីយេ ទទួលគោរមងារសាសនា <ទំព័រ៖ ១៧

■ ព្រះវិហារសន្តយ៉ូហានបាទីស្ត នៅប៉ូស្រោសម្លោធជាផ្លូវការ <ទំព័រ៖១៨


# អ្នកនាំសារ
# the messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

ខែ មេសា | ឆ្នាំ ២០២២ | លេខទី ១៥០

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

April, 2022 | #150


## ពិធីបុណ្យជ្រមុជទឹក ក្នុងឱកាសបុណ្យចម្លង



លោកអភិបាលទេព ច័ន្ទពិសិដ្ឋ ធ្វើអគ្គសញ្ញាជ្រមុជទឹកដល់បេក្ខជនចំនួន២៣នាក់
នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ (ពេទ្យយាយជី) នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២។
អគ្គសញ្ញាជ្រមុជទឹក គឺដើម្បីឱ្យបេក្ខជនក្លាយជាគ្រីស្តបរិស័ទ និងរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្តនិងព្រះសហគមន៍របស់ព្រះអង្គអស់មួយជីវិត៕

■ «ក្ដីសង្ឃឹម ហ៊ុន ម៉ានី» បង្ហាញពីចក្ខុវិស័យ ឆន្ទៈ និងការប្ដេជ្ញាចិត្តចំពោះការកសាងមាតុប្រទេស

ទំព័រ-៣



■ អ្នកព័ត៌មានឯករាជ្យនៅតែត្រូវបានឃាំឃាំង និងដៅមុខ ប៉ុន្តែមន្ត្រីរដ្ឋាភិបាលថា មិនត្រឹមត្រូវ

ទំព័រ-៥

■ ព្រះសហគមន៍ប្រារព្ធពិធីបុណ្យហែស្លឹកដើម្បីនឹកដល់ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

ទំព័រ-១៥



# គ្រីស្តបរិស័ទ និងសុខភាពផ្លូវវិញ្ញាណ

មនុស្សជាច្រើនបានចាប់អារម្មណ៍យ៉ាងខ្លាំងអំពីសុខភាពផ្លូវកាយរបស់ខ្លួន ដោយហាត់ប្រាណទៀងទាត់ គ្រប់គ្រងរបបអាហារត្រឹមត្រូវ ប៉ុន្តែគ្រូពេទ្យជំនាញខាងចិត្តវិទ្យាបានលើកឡើងថា ប៉ុណ្ណឹងមិនគ្រប់គ្រាន់ទេ ពួកគេត្រូវការសុខភាពផ្លូវចិត្តល្អប្រសើរផងដែរ។

តាមការរៀបរាប់របស់អ្នកនិពន្ធ ឈ្មោះចូ ម៉ាកឆេន (Jo Marchant) ក្នុងសៀវភៅ The Human Cosmos បានឱ្យដឹងថា វាមិនចម្លែកទេដែលថា ចិត្តក៏អាចប៉ះពាល់ដល់មុខងារសរីរវិទ្យាដូចជាការរំលាយអាហារ របត់ឈាមរត់ និងប្រព័ន្ធការពាររាងកាយ។ ដំណើរការទាំងអស់នេះត្រូវបានគ្រប់គ្រងដោយខួរក្បាលតាមរយៈប្រព័ន្ធសរសៃប្រសាទស្វយ័ត។ អារម្មណ៍តានតឹង ឬភ័យខ្លាចអាចបណ្តាលឱ្យបេះដូងរបស់អ្នករត់ ហើយពោះវៀនរបស់អ្នកទទេ ហើយបង្កការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំដែលហៅថាការរលាក។ នេះគ្រាន់តែជាឧទាហរណ៍តូចមួយសម្រាប់ការរិះគិតរបស់យើងជាគ្រីស្តបរិស័ទ គិត និងរៀបចំផ្លូវវិញ្ញាណរបស់យើងឱ្យបានល្អប្រសើរ។

*តើរៀបចំផ្លូវវិញ្ញាណយ៉ាងណា?*

បើយើងទៅជួបលោកបូជាចារ្យ ឬអ្នកបួសអស់លោកពិតជាណែនាំយើងឱ្យរក្សាទំនាក់ទំនងជាមួយព្រះជាម្ចាស់ដោយការអធិដ្ឋាន។ ពិតមែនការអធិដ្ឋានដែលយើងតែងគិតថា ជារឿងគួរឱ្យធុញទ្រាន់ មិនអីចឹងឬ? ឬយើងអាចនិយាយថាគ្មានអ្វីត្រូវអធិដ្ឋានទេ គ្មានអ្វីត្រូវនិយាយផង?

នៅក្នុងជីវិតរស់នៅជាក់ស្តែង អស់អ្នកដែលមានបទពិសោធធ្លាប់នៅម្នាក់ឯងពិតជាយល់ច្បាស់ថា ពិតមែន ខ្ញុំត្រូវការនិយាយជាមួយនរណាម្នាក់ ខ្ញុំត្រូវការម្នាក់គ្រាន់តែស្តាប់ខ្ញុំ នោះខ្ញុំស្កប់ចិត្តហើយ។

*តើម្នាក់នោះជានរណា?*

បងប្អូនអាចជ្រើសរើសមិត្តភក្តិជិតស្និទ្ធណាម្នាក់និយាយរឿងនេះ។ ចុះហេតុអ្វីបងប្អូនមិនដាក់អាទិភាពនៃមិត្តភក្តិម្នាក់នោះជាព្រះជាម្ចាស់របស់យើង ដែលយើងតែងប្រកាសថា ព្រះអង្គមានព្រះជន្មគង់នៅតាំងពីដើមរៀងមក រហូតអវសាន្តកាលនៃពិភពលោក?

ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ចៀមរបស់ខ្ញុំស្គាល់ខ្ញុំ (យហ១០,១៤)។ ក្រោយពេលសាវ័ក៧២រូបត្រឡប់មកពីផ្សាយដំណឹងល្អវិញ ពួកគេបានមកទូលព្រះអង្គអំពីកិច្ចការទាំងឡាយដែលបានធ្វើ (លក១០,១៧)។ ក្នុងជីវិតរបស់យើងប្រចាំថ្ងៃ យើងបានធ្វើកិច្ចការជាច្រើនតាំងតែពីពេលភ្ញាក់ពីដំណេក រហូតដល់ចូលដំណេកវិញ ដូច្នេះ យើងមានពាក្យជាច្រើនដើម្បីទូលថ្វាយព្រះយេស៊ូ។ មានលោកបូជាចារ្យម្នាក់ បានប្រាប់គ្រីស្តបរិស័ទក្នុងធម្មទេសនារបស់លោកថា កុំអធិដ្ឋានយូរអី លើកលែងតែរិះគិតពិចារណាស៊ីជម្រៅប៉ុណ្ណោះ ប៉ុន្តែពេលកូនៗក្រោកពីដំណេកពេលព្រលឹម សូមនិយាយទៅកាន់ព្រះយេស៊ូថា «អរុណសួស្តីព្រះអម្ចាស់! សូមព្រះអង្គជួយកូនដើម្បីធ្វើកិច្ចការងារល្អៗសម្រាប់ថ្ងៃនេះ» ហើយមុនពេលចូលដំណេកចូរកូនទូលព្រះអង្គថា «កូនសូមអរព្រះគុណព្រះអង្គដែលបានគង់នៅជាមួយកូនពេញមួយថ្ងៃនេះ ទោះពេលនេះ កូនកំពុងមានទុក្ខព្រួយក៏ដោយ តែកូនជឿថា ព្រះអង្គមិនបោះបង់កូនឡើយ»។

ពាក្យអធិដ្ឋានសាមញ្ញៗ អាចជួយអោយយើងនៅក្បែរ និងស្គាល់ព្រះជាម្ចាស់បានយ៉ាងពិសេសបំផុត។ ខ្ញុំអាចធ្វើបាន! ហើយខ្ញុំក៏អាចបង្រៀនកូនចៅរបស់ខ្ញុំឱ្យធ្វើដូចគ្នាដែរ ដើម្បីឱ្យសេចក្តីស្រឡាញ់របស់យើងបានរួមគ្នាក្នុងអង្គនៃព្រះជាម្ចាស់តែមួយ។

ក្រៅពីរក្សាទំនាក់ទំនងជាមួយព្រះជាម្ចាស់នៃយើង យើងក៏ត្រូវតែរក្សាសម្ពន្ធភាពមនុស្សនៅជុំវិញខ្លួនយើងដែរ ការអត់ធ្មត់ ការតាំងចិត្តកែប្រែអ្វីមួយជាប្រចាំថ្ងៃ ការស៊ូទ្រាំនឹងការរងទុក្ខលំបាក ការដោះស្រាយដោយសន្តិវិធី ការប្រើប្រាស់ពាក្យពីរោះចំពោះមនុស្សគ្រប់គ្នា គឺជាគុណធម៌តូចៗដែលយើងជាគ្រីស្តបរិស័ទអាចធ្វើបានដើម្បីបង្ហាញអំពីវត្តមានរបស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងឡាយ។ សូមបង្ហាញព្រះបិតាឱ្យយើងខ្ញុំបានឃើញផង (យហ១៤,៨)។

នេះជាពាក្យសម្តីរបស់សាវ័កម្នាក់ឈ្មោះ ភីលីព ហើយពាក្យនេះ ក៏នឹងដង្ហោយរកយើងគ្រប់ពេលវេលាក្នុងនាមជាគ្រីស្តបរិស័ទ។ ដើម្បីឱ្យការណ៍នេះសម្រេចបាន យើងចាំបាច់ត្រូវពង្រឹងផ្លូវវិញ្ញាណរបស់យើងឱ្យមាំទាំ ហើយប្រព្រឹត្តដោយក្តីសប្បុរសចំពោះមនុស្សគ្រប់គ្នា៕



CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# អតីតមេបញ្ជាការ UNTAC មកទស្សនាកម្ពុជា អបអរទំនាក់ទំនងការទូតកម្ពុជា-អូស្ត្រាលី

*អត្ថបទ៖ អមរិន្ទ ដានុត*

លោកឧត្តមសេនីយ៍ឯក ចន សេនដឺសុន (Jonh Sanderson) អតីតមេបញ្ជាការរបស់កង កម្លាំងអន្តរជាតិ UNTAC អតីតមេបញ្ជាការកងទ័ពអូស្ត្រាលី និងជាអតីតអភិបាលរដ្ឋ Western Australia បានកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះការអភិវឌ្ឍដ៏ឆាប់រហ័សនៅកម្ពុជា និងបានកោតសរសើររាជរដ្ឋាភិបាលកម្ពុជាចំពោះយុទ្ធនាការចាក់វ៉ាក់សាំង ប្រកបដោយជោគជ័យផងដែរ។



លោកថ្លែងដូចនេះ ក្នុងជំនួបនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ នៅទីស្តីការក្រសួង ជាមួយលោកប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

លោក ចន សេនដឺសុន បានលើកឡើងដោយលោកបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងឋានៈជាប្រធានអាស៊ាន និងលោក ប្រាក់ សុខុនក្នុងឋានៈជាប្រេសិតពិសេសរបស់ប្រធានអាស៊ានសម្រាប់មីយ៉ាន់ម៉ា ក្នុងការស្វែងរកដំណោះស្រាយសម្រាប់វិបត្តិបច្ចុប្បន្ននៅមីយ៉ាន់ម៉ា ជាពិសេសតាមរយៈការប្រើប្រាស់បទពិសោធន៍របស់កម្ពុជា។

ជាមួយគ្នានោះដែរ លោក ប្រាក់ សុខុន ក៏បានកោតសរសើរចំពោះការរួមចំណែកយ៉ាងសំខាន់របស់អូស្ត្រាលី ជាពិសេសលោក ចន សេនដឺសុន ដែលក្នុងតួនាទីពេលនោះជាមេបញ្ជាការរបស់កងកម្លាំងអន្តរជាតិនៃអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) នៅក្នុងដំណើរការសន្តិភាពនៅកម្ពុជា។

នាឱកាសនោះដែរ លោក ប្រាក់ សុខុន បានរំលឹកឡើងវិញនូវសមិទ្ធផលនានាដែល UNTAC សម្រេចបាននៅកម្ពុជា ក្នុងការអនុវត្តគោលដៅសំខាន់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស រួមទាំងការរៀបចំការបោះឆ្នោតសកលនៅឆ្នាំ១៩៩៣ បើទោះបីជាមានការធ្វើពហិការរបស់ក្រុមខ្មែរក្រហម និងការបន្តសង្គ្រាមបែបឧទ្ទាមរបស់ពួកនេះក៏ដោយ។

លោកបានគូសបញ្ជាក់ថា ៖ «ក្រោយការដកចេញពីកម្ពុជារបស់ UNTAC សម្តេចតេជោនាយករដ្ឋមន្ត្រីបានដាក់ចេញនូវគោលនយោបាយឈ្នះ-ឈ្នះ ដែលបាននាំមកនូវការបង្រួបបង្រួមជាតិ សន្តិភាពពេញលេញ និងស្ថិរភាពទាំងស្រុងនៅក្នុងប្រទេសនៅឆ្នាំ១៩៩៨»។

លោកឧត្តមសេនីយ៍ឯក ចន សេនដឺសុន អតីតមេបញ្ជាការរបស់កង កម្លាំងអន្តរជាតិ UNTAC អតីតមេបញ្ជាការកងទ័ពអូស្ត្រាលី និងជាអតីតអភិបាលរដ្ឋ Western Australia ដែលអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧០ នៃទំនាក់ទំនងការទូតកម្ពុជា-អូស្ត្រាលី និងខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើត UNTAC ផងដែរ ។

ទន្ទឹមនឹងនោះដែរ លោក ប្រាក់ សុខុន ក៏បានជម្រាបជូនលោក សេនដឺសុន ផងដែរ អំពីមោទនភាព របស់កម្ពុជា ក្នុងការប្រែក្លាយពីប្រទេសដែលទទួលយកកងកម្លាំងថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ទៅជាប្រទេសមួយដែលរហូតមកដល់ពេលនេះបានបញ្ជូនកងកម្លាំងកម្ពុជាជាង៨ពាន់នាក់ ទៅចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅប្រទេសចំនួន៨ នៅទ្វីបអាហ្វ្រិក និងមជ្ឈិមបូព៌ា។

ទន្ទឹមនឹងនោះដែរ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានជួបជាមួយនឹងលោក ចន សេនដឺសុន ផងដែរ ដោយក្នុងជំនួបនេះ លោក ចន សេនដឺសុន បង្ហាញពីក្តីរំភើប ដែលបានវិលត្រឡប់មកកម្ពុជាវិញ និងជាប្រទេសដែលលោកមានអនុស្សាវរីយ៍ និងមានមិត្តភ័ក្តិយ៉ាងច្រើនស្របពេលជាមួយខួប ៣០ឆ្នាំ នៃប្រតិបត្តិការស្វែងរកសន្តិភាពនៅកម្ពុជា និងខួប ៧០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងកម្ពុជានិងអូស្ត្រាលី។

លោក ចន សេនដឺសុន លើកឡើងដែរថា ៖ «កម្ពុជាមានការផ្លាស់ប្តូរដ៏អស្ចារ្យជាពិសេសរាជធានីភ្នំពេញ ដែលមានការអភិវឌ្ឍដ៏ស្រស់បំព្រង ស្របគ្នានឹងការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់កម្ពុជានៅទូទាំងប្រទេស។ ជាមួយការចូលរួមចំណែកក្នុងកិច្ចការពិភពលោក កិច្ចការតំបន់ និងជាពិសេស ប្រធានអាស៊ានទាំងនេះជាវឌ្ឍនភាព និងជោគជ័យដ៏ធំធេងរបស់កម្ពុជា»។

ជាការឆ្លើយតប សម្តេច ហ៊ុន សែន បានថ្លែងអំណរគុណ លោកសេនដឺសុន និងរដ្ឋាភិបាលអូស្ត្រាលី ដែលបានចូលរួមចំណែកក្នុងការស្វែងរកសន្តិភាពរបស់កម្ពុជា ការទទួលស្គាល់កម្ពុជា មុនកម្ពុជាទទួលបានឯករាជ្យ និងបោះបង់ការទទួលស្គាល់ខ្មែរក្រហមនៅអង្គការសហប្រជាជាតិមុនគេ។

សម្តេច បានមានប្រសាសន៍ថា ៖ «ប្រទេសអូស្ត្រាលី ជាប្រទេសបានទទួលស្គាល់កម្ពុជាមុនកម្ពុជាទទួលបានឯករាជ្យ ជាប្រទេសដែលជួយកម្ពុជាឲ្យទទួលបានឯករាជ្យ»៕

# សៀវភៅ «ក្តីសង្ឃឹម ហ៊ុន ម៉ានី» បង្ហាញពីចក្ខុវិស័យ ឆន្ទៈ និងការប្តេជ្ញាចិត្តរបស់លោក ចំពោះការកសាងមាតុប្រទេស

*អត្ថបទ៖ អមរិន្ទ ដានុត*

សៀវភៅដែលមានចំណងជើងថា «ក្តីសង្ឃឹម ហ៊ុន ម៉ានី» ដែលត្រូវបាននិពន្ធដោយ លោក លាង ដឺលុច ដែលជាសហស្ថាបនិក និងជាចាងហ្វាង ការផ្សាយនៃសារព័ត៌មានឌីជីថលថ្មីៗ ត្រូវបានប្រកាសដាក់លក់ជាផ្លូវការ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២។

សារព័ត៌មានឌីជីថលថ្មីៗ (thmeythmey.com) បានទទួលសិទ្ធិពីអ្នកនិពន្ធដើម្បីបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថា «ក្តីសង្ឃឹម ហ៊ុន ម៉ានី» ចំនួន ១០ ០០០ ច្បាប់ ដាក់លក់នៅលើទីផ្សារ។






លោក គី សុខលីម សហស្ថាបនិកនៃសារព័ត៌មានថ្មីៗបានពន្យល់ថា សារព័ត៌មានថ្មីៗបានចាប់ អារម្មណ៍លើស្នាដៃរបស់លោក លាង ដឺលុច ដែលជាអ្នកកាសែតដ៏មានពិសោធន៍មួយរូប។ លោកបន្តថា ព្រោះតែលោក ហ៊ុន ម៉ានី គឺជាអ្នកនយោបាយបន្តវេនមួយរូបដ៏គួរឱ្យចាប់អារម្មណ៍ក្នុងចំណោមមហាជនផង ដូច្នេះហើយបានជាសារព័ត៌មានថ្មីៗសម្រេចចិត្តវ៉ាប់រងលើការបោះពុម្ព និងបញ្ចេញស្នាដៃស្នាដៃមួយ នេះទៅលើទីផ្សារអំណាន។

ចំណែកលោក លាង ដឺលុចដែលជាអ្នកនិពន្ធ សៀវភៅមួយក្បាលដែលមានរហូតដល់២៥៥ ទំព័រ ក៏បានលើកឡើងដែរថា លោកសប្បាយចិត្តនៅពេលដែលសារព័ត៌មានថ្មីៗ ទទួលយកការបោះពុម្ពស្នាដៃដំបូងរបស់លោកនេះ។

លោកជឿជាក់ថា អ្នកអានប្រាកដជាបានស្គាល់ទឹកចិត្ត គំនិត សេចក្តីស្នេហាចំពោះប្រទេស និងប្រជាជនរបស់តួអង្គហ៊ុន ម៉ានី ដែលជាអ្នក នយោបាយបន្តវេនមួយរូប បានយ៉ាងច្បាស់។ ហេតុអ្វីបានជាលោក ដឺលុច សរសេរអំពីលោក ហ៊ុន ម៉ានី? លោកពន្យល់ថា៖ «ក្នុងចំណោមកូនប្រុសទាំង៣របស់សម្តេច ហ៊ុន សែន និងសម្តេច ប៊ុន រ៉ានី លោក ហ៊ុន ម៉ានី បានលេចមុខជួយកិច្ចការឪពុក ជាសាធារណៈមុនគេ តាមរយៈតួនាទីជាជំនួយការផ្ទាល់»។

លោក លាង ដឺលុច បានពន្យល់បន្ថែមថា បន្ទាប់មកស្រាប់តែលោក ម៉ានី ជាប់ឆ្នោតជាតំណាងរាស្ត្រដែលជាកិច្ចការនយោបាយជាន់ខ្ពស់តែម្តង។ ទន្ទឹមគ្នានេះ លោក ម៉ានី មានប្រជាប្រិយភាពខ្លាំងក្នុងចំណោមយុវជនតាមរយៈសកម្មភាពសង្គម និងមនុស្សធម៌។

លោកបានបញ្ជាក់ថា៖«ខ្ញុំយល់ឃើញថា លោក ម៉ានី គឺជាអ្នកនយោបាយដ៏មានសក្តានុពលមួយរូបក្នុងពេលអនាគត។ ដូច្នេះសម្រាប់ខ្ញុំគេគួរស្គាល់ និងយល់ពី លោក ហ៊ុន ម៉ានី»។

បន្ទាប់ពីបានតាមដាន និងសង្កេតសកម្មភាពរបស់លោក ម៉ានី តាំងពីឆ្នាំ ២០១៣មក អ្នកនិពន្ធរូបនេះ បានប្រើរយៈពេល២ឆ្នាំ (២០២០ និង២០២១) ដើម្បីនិពន្ធសៀវភៅដែលនិយាយអំពីចក្ខុវិស័យ ឆន្ទៈ និង ការប្តេជ្ញាចិត្តរបស់លោក ហ៊ុន ម៉ានី ចំពោះការកសាងមាតុប្រទេសរបស់លោកឱ្យបានកាន់តែប្រសើរ សម្រាប់ប្រជាជន។

លោក លាង ដឺលុច បានជួបសម្ភាសន៍លោក ម៉ានី ជាច្រើនដង ព្រមទាំងអ្នកដែលធ្លាប់ស្គាល់ និងធ្វើការងារជាមួយលោក ម៉ានី ទៀតផង ដើម្បីប្រមូលព័ត៌មានអំពីលោក ម៉ានី។

លោក លាង ដឺលុច អះអាងយ៉ាងដូច្នេះថា៖ «នៅពេលដែលលោកអ្នកអានសៀវភៅនេះ លោកអ្នក នឹងស្គាល់អំពីអត្តចរិត របៀបនៃការពិចារណារបស់លោក ហ៊ុន ម៉ានី, ជីវភាពខ្លះៗរបស់គ្រួសារនាយកនាយករដ្ឋមន្ត្រី ជាពិសេសជីវិតរបស់លោក ម៉ានី»។

អ្នកនិពន្ធដដែលបន្តថា៖ «តួអង្គ ហ៊ុន ម៉ានី ក៏រស់នៅ ក្នុងសម្ពាធនៃការរិះគន់ពីមតិជាច្រើន ដែលសម្លឹងមើលលោកត្រឹមតែជាកូននាយករដ្ឋមន្ត្រី ដែលមានបុណ្យ សិទ្ធិជាច្រើន។ ផ្ទុយទៅវិញ ព្រោះតែជាកូនមេដឹកនាំកំពូលនេះហើយ ដែលលោក ម៉ានី ត្រូវធ្វើការកាន់តែច្រើន ដើម្បីកិត្តិយសគ្រួសារផង និងដើម្បីអាចបង្កើតបានកន្លែងឈរជើងសម្រាប់ខ្លួនឯងក្នុងនាមជាអ្នក នយោបាយបន្តវេនដ៏មានឥទ្ធិពលផង»។

អ្វីដែលជាលក្ខណៈពិសេសផងដែរនៅក្នុងសៀវភៅ «ក្តីសង្ឃឹម ហ៊ុន ម៉ានី» នេះ គឺអ្នកអានក៏អាច បានស្គាល់អំពីបុគ្គលលក្ខណៈខ្លះៗរបស់សម្តេចតេជោ ហ៊ុន សែន តាមរយៈការរៀបរាប់ពិពណ៌នារបស់ លោក ហ៊ុន ម៉ានី៕

# សត្វក្តាន់ដ៏កម្រជិត១០០ក្បាល ត្រូវបានអ្នកជំនាញរកឃើញ នៅតំបន់ព្រៃទេសភាពមេគង្គកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

សត្វក្តាន់ជិត១០០ ក្បាលត្រូវបានអ្នកវិទ្យាសាស្ត្រតាមដានឃើញរស់នៅក្នុងតំបន់ទីជម្រកព្រៃវាលស្មៅនៃតំបន់ព្រៃទេសភាពមេគង្គក្នុងខេត្តក្រចេះ ដែលត្រូវបានរាយការណ៍កាលពីចុងខែមេសាកន្លងទៅនេះ ដែលមានការបញ្ជាក់ដោយរូបភាពទទួលបានពីការតាមដានសត្វក្តាន់ដោយប្រើម៉ាស៊ីនថតស្វ័យប្រវត្តិ និងបច្ចេកវិទ្យាដ្រូនដែលបំពាក់ម៉ាស៊ីនថតប្រើកំដៅ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ (WWF) បានឱ្យដឹងថាសត្វក្តាន់ដែលជាសត្វកម្រនៅលើពិភពលោកកំពុងរស់នៅតំបន់ព្រៃទេសភាពមេគង្គកម្ពុជា ដែលសត្វក្តាន់ចំនួនប្រមាណជា ៧០ ក្បាលត្រូវបានរកឃើញ។

> សត្វក្តាន់ត្រូវបានកំណត់ក្នុងបញ្ជីក្រហមរបស់អង្គការ **IUCN** ថាជាប្រភេទសត្វរងគ្រោះថ្នាក់ជិតផុតពូជជាសកល ហើយនៅក្នុងប្រទេសកម្ពុជា សត្វក្តាន់នេះធ្លាប់ត្រូវបានអ្នកវិទ្យាសាស្ត្រប៉ាន់ប្រមាណថាបានផុតពូជទៅហើយរហូតដល់មានការរកឃើញឡើងវិញនៅក្នុងឆ្នាំ ២០០៦ នៅក្នុងខេត្តក្រចេះ













កម្មវិធីស្រាវជ្រាវ ត្រូវបានអនុវត្តដោយអ្នកជំនាញផ្នែកស្រាវជ្រាវសត្វព្រៃនៃមន្ទីរបរិស្ថានខេត្តក្រចេះ និងអង្គការ WWF ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងចូលរួមពីក្រុមអ្នកជំនាញអភិរក្សជីវចម្រុះ BINCO ក្រុមអ្នកជំនាញបច្ចេកវិទ្យាដ្រូននៃម៉ាស៊ីនថតប្រើកំដៅ DRONES GmbH ក៏ដូចជាពីសំណាក់សហគមន៍ និងអាជ្ញាធរមូលដ្ឋានក្នុងតំបន់នៃដែនជម្រកសត្វព្រៃដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដោយមានការគាំទ្រពីអង្គការ WWF ។

អង្គការWWF បានលើកឡើងថា៖ «លទ្ធផលនៃការស្រាវជ្រាវក៏បានបង្ហាញផងដែរពីវត្តមាននៃសត្វក្តាន់វ័យជំទង់ និងកូនជាច្រើនផងដែរ ដែលជាកត្តាចង្អុលបង្ហាញពីការបន្តពូជរបស់សត្វដ៏កម្រប្រភេទនេះនៅក្នុងតំបន់ទីជម្រក»។

សត្វក្តាន់ត្រូវបានកំណត់ក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទសត្វរងគ្រោះថ្នាក់ជិតផុតពូជជាសកល ហើយនៅក្នុងប្រទេសកម្ពុជា សត្វក្តាន់នេះធ្លាប់ត្រូវបានអ្នកវិទ្យាសាស្ត្រប៉ាន់ប្រមាណថាបានផុតពូជទៅហើយរហូតដល់មានការរកឃើញឡើងវិញនៅក្នុងឆ្នាំ ២០០៦ នៅក្នុងខេត្តក្រចេះ។

ទោះជាយ៉ាងណាក៏ដោយ សត្វនេះបាន និងកំពុងទទួលរងការគំរាមកំហែងដោយការបាត់បង់ទីជម្រក ការបរបាញ់ និងវិបត្តិអន្ទាក់ ដែលបានរាលដាលឡើងដោយការជួញដូរសត្វព្រៃខុសច្បាប់។ ដើម្បីជួយសង្គ្រោះសត្វក្តាន់ និង សត្វព្រៃសំខាន់ៗជាសកលជាច្រើនប្រភេទទៀតក្នុងប្រទេសកម្ពុជាពីការបរបាញ់ និងការដាក់អន្ទាក់ យុទ្ធនាការ «អន្ទាក់-សូន្យក្នុងតំបន់ការពារធម្មជាតិកម្ពុជា»ត្រូវបានរៀបចំឡើង និងបើកឲ្យដំណើរការជាផ្លូវការកាលពីដើមខែមីនាឆ្នាំ២០២២កន្លងទៅនេះ ដោយមានគោលដៅលុបបំបាត់ការដាក់អន្ទាក់គ្រប់ប្រភេទ និងបញ្ចប់ការជួញដូរសត្វព្រៃខុសច្បាប់៕

# សត្វព្រៃកម្រជាច្រើន ត្រូវបានរកឃើញដោយម៉ាស៊ីនថតស្វ័យប្រវត្តិនៅក្នុងព្រៃទេសភាព

*អត្ថបទ៖ អមរិន្ទ ដានុត*

សត្វកម្រជាច្រើនប្រភេទ ត្រូវបានការរកឃើញនៅក្នុងតំបន់ព្រៃទេសភាពខ្ពង់រាបភាគខាងកើតត្រឹមខែមេសានេះ ដោយបានបញ្ជាក់តាមរយៈរូបថតដ៏កម្រដែលថតដោយម៉ាស៊ីនថតស្វ័យប្រវត្តិ ដែលធ្វើឱ្យក្រុមអ្នកជំនាញស្រាវជ្រាវសត្វព្រៃនៃមន្ទីរបរិស្ថានខេត្តមណ្ឌលគិរីនៃក្រសួងបរិស្ថាន និងអង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ (WWF) មានក្តីរំភើបជាខ្លាំង។

ក្រសួងបរិស្ថាន បានឱ្យដឹងថា ក្រុមមន្ត្រីបរិស្ថាននិងអង្គការ WWF មានការសប្បាយចិត្ត និងរំភើបជាពន់ពេក ខណៈដែលពួកគេបានផ្តល់សេចក្តីរាយការណ៍ពីលទ្ធផលនៃការតាមដានសត្វព្រៃនៅក្នុងតំបន់ព្រៃទេសភាពខ្ពង់រាបភាគខាងកើតត្រឹមខែមេសានេះ ដោយបានបញ្ជាក់ពីវត្តមានរបស់សត្វខ្លារខិនញី១ក្បាលតាមរយៈរូបថតដ៏កម្រដែលថតដោយម៉ាស៊ីនថតស្វ័យប្រវត្តិ។

លទ្ធផលនៃការតាមដានសត្វព្រៃក៏បានបង្ហាញផងដែរពីវត្តមាននៃពពួកសត្វក្រចកជើងចំពាម្យួមមានសត្វប្រើសដែលជាប្រភេទសត្វកម្រ សត្វជ្រូកព្រៃ សត្វឈ្លូស ក៏ដូចជាសត្វស្លាប និងស្វាក្តាមផងដែរ។

ក្រសួងបរិស្ថានបានបញ្ជាក់ថា ៖ «សត្វខ្លារខិនត្រូវបានចាត់ថ្នាក់ក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទសត្វរងគ្រោះថ្នាក់ជិតផុតពូជបំផុត ហើយចំនួនវាត្រូវបានបាត់បង់ពីទីជម្រកដែលវាធ្លាប់រស់នៅនៃប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ តំបន់ព្រៃទេសភាពខ្ពង់រាបភាគក្នុងប្រទេសកម្ពុជាគឺជាទីជម្រកចុងក្រោយសម្រាប់ប្រភេទសត្វខ្លារខិននេះ ដែលអ្នកវិទ្យាសាស្ត្រជឿថានៅសេសសល់ចំនួនតិចតួចបំផុត»។

បើទោះជាយ៉ាងនេះក្តី សត្វមំសាសីដ៏កម្របំផុតមួយប្រភេទនេះកំពុងបន្តទទួលរងការគំរាមកំហែងនឹងការផុតពូជដោយសារវិបត្តិអន្ទាក់ដែលបានរាលដាលឡើងដោយការជួញដូរសត្វព្រៃខុសច្បាប់។

សត្វខ្លារខិនអាចប្រឈមមុខនឹងជោគវាសនាដូចគ្នានឹងសត្វខ្លាធំដែលបានផុតពូជទៅហើយ ដោយហេតុថាចំនួននៅសេសសល់ដ៏តិចតួចបំផុតរបស់វានៅក្នុងប្រទេសកម្ពុជាកំពុងប្រឈមនឹងហានិភ័យខ្ពស់នៃការជាប់អន្ទាក់ដែលបានលាក់បង្កប់ខ្លួនយ៉ាងស្ងៀមស្ងាប់នៅក្នុងជម្រកព្រៃហើយរង់ចាំស្ទាក់ចាប់ និងសំលាប់សត្វគ្រប់ប្រភេទទាំងអស់រួមទាំងសត្វខ្លារខិន សត្វក្រចកជើងចំពាម និងសត្វព្រៃផ្សេងៗទៀតដោយមិនរើសមុខឡើយ។

ក្រសួងដដែលនេះបានបន្តថា ដើម្បីដោះស្រាយវិបត្តិនេះ តួអង្គសំខាន់ៗនៃស្ថាប័នរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធ និងអង្គការអន្តរជាតិជាដៃគូក្នុងវិស័យបរិស្ថានបានបើកយុទ្ធនាការ«អន្ទាក់-សូន្យក្នុងតំបន់ការពារធម្មជាតិកម្ពុជា»កាលពីដើមខែមីនាឆ្នាំ២០២២កន្លងទៅនេះ ដោយបានប្តេជ្ញាចិត្តរួមគ្នាបញ្ចប់វិបត្តិអន្ទាក់ និងការជួញដូរសត្វព្រៃខុសច្បាប់ ដើម្បីការពារអនាគតប្រជាជន និងការរស់រានរបស់សត្វព្រៃកម្ពុជា៕

# អង្គការសរព័ត៌មានថាអ្នកព័ត៌មានឯករាជ្យនៅតែត្រូវបានយាយីនិងដៅមុខ ប៉ុន្តែមន្ត្រីរដ្ឋាភិបាលថា មិនត្រឹមត្រូវ



*អត្ថបទ៖ អមរិន្ទ ដានុត*

ចាប់ពីខែមករាដល់ខែមីនា ឆ្នាំ២០២២នេះ សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ហៅកាត់ថាខេមបូចា បានកត់ត្រាករណីនៃការយាយីមកលើអ្នកសារព័ត៌មាន ដែលមានចំនួនរហូតដល់២៣នាក់ក្នុងនោះមានស្ត្រីចំនួន៣នាក់។

នេះបើយោងតាមរបាយការណ៍ឃ្លាំមើលប្រចាំត្រីមាសស្តីពី ស្ថានភាពអ្នកសារព័ត៌មាននៅកម្ពុជា ដែលបានចេញផ្សាយនាថ្ងៃទី២៩ ខែមេសា ដោយសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)។

របាយការណ៍ដដែលបានលើកឡើងថា អ្នកសារព័ត៌មានចំនួន៥នាក់ក្នុងចំណោមពួកគេទាំង២៣នាក់នេះ ត្រូវបានចាប់ខ្លួន ដែល៤នាក់ប្រឈមនឹងវិធានការច្បាប់១១នាក់ រងអំពើហិង្សានិងការយាយី ហើយអង្គភាពសារព័ត៌មានចំនួន៣ត្រូវបានដកហូតអាជ្ញាបណ្ណ។

ខេមបូចា បានបញ្ជាក់ថា ៖ «ការភ័យខ្លាចពីបញ្ហាផ្លូវច្បាប់នៅតែកើតឡើងជាប្រចាំនៅក្នុងការបំពេញការងារ ក្នុងចំណោមបញ្ហាប្រឈមជាច្រើនផ្សេងទៀតដែលអ្នកសារព័ត៌មានកម្ពុជាកំពុងជួបប្រទះ។ អ្នកសារព័ត៌មានតែងតែមានអារម្មណ៍ថាខ្លួនរងការបំភិតបំភ័យឬការគំរាមកំហែងដោយសារវិធានការរបស់រដ្ឋាភិបាល»។

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) បានមានប្រសាសន៍ថា ៖ «យើងសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យយកចិត្តទុកដាក់បន្ថែមទៀត និងគោរពសេរីភាពសារព័ត៌មាន ជាពិសេសផ្តល់ការការពារពេញលេញ និងឈប់រារាំងការអនុវត្តសិទ្ធិនិងសេរីភាពរបស់អ្នកសារព័ត៌មាន»។

ទន្ទឹមនឹងនេះដែរ អង្គការសរព័ត៌មានបានរកឃើញថា អ្នកសារព័ត៌មានឯករាជ្យកំពុងប្រឈមនឹងការលំបាកក្នុងការបំពេញការងាររបស់ពួកគេក្នុងការផ្តល់ព័ត៌មានពិតដល់សាធារណជន។ ទោះបីជាយ៉ាងណា មន្ត្រីរដ្ឋាភិបាលបានលើកឡើងថា របាយការណ៍នេះមិនបានឆ្លុះបញ្ចាំងពីសេរីភាពសារព័ត៌មាននៅកម្ពុជាទេ។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ (CCIM) បានរកឃើញថា បញ្ហាប្រឈមរួមមានការគាបសង្កត់ផ្នែកនយោបាយ សម្ពាធរដ្ឋាភិបាល និងបញ្ហាផ្លូវច្បាប់ផ្សេង។ យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២១ របស់CCIM ស្តីពីបញ្ហាប្រឈមចំពោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែលចេញផ្សាយនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជាក្នុងឆ្នាំ២០២១ គឺអាក្រក់ជាងឆ្នាំ២០២០ ។

ចំណែកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានលើកឡើងដែរថា នៅប្រទេសកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យត្រូវបានរងការដៅមុខសញ្ញា។ របកគំហើញរបស់ ម.ស.ម.ក នាពេលថ្មីៗនេះបង្ហាញថា សេរីភាពសារព័ត៌មានរងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបញ្ជាក់ថា ៖ «អ្នកសារព័ត៌មានដែលធ្វើការនៅក្នុងប្រទេសកម្ពុជាតែងតែរងការបំភិតបំភ័យ ឃ្លាំមើល គំរាម និងយាយីតាមប្រព័ន្ធតុលាការចំពោះការបំពេញការងារស្របច្បាប់របស់ខ្លួន»។

ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ម.ស.ម.ក បានកត់ត្រាទុកថា មានអ្នកសារព័ត៌មានយ៉ាងហោចណាស់ ចំនួន៩នាក់ដែលបានប្រឈមនឹងការយាយីតាមប្រព័ន្ធតុលាការ ដែលរួមមាន ការគំរាមកំហែង និងការ កោះហៅពីតុលាការ រហូតដល់ការចាប់ខ្លួនតាមអំពើចិត្ត និងការផ្តន្ទាទោសដោយហេតុផលនយោបាយ ហើយអាជ្ញាប័ណ្ណសារព័ត៌មានចំនួនប្រាំពីរត្រូវបានដកហូតដោយក្រសួងព័ត៌មានផងដែរ។

ប្រភពដដែលបានបន្តថា ៖ «លើសពីនេះ អ្នកសារ ព័ត៌មានបានប្រឈមនឹងឧបសគ្គផ្សេងៗក្នុងការទទួលព័ត៌មានដែលកាន់កាប់ដោយអាជ្ញាធរកម្ពុជា។ ជាងនេះ ទៅទៀត យុត្តិធម៌ក៏ពុំទាន់ត្រូវបានផ្តល់ឱ្យអ្នកសារព័ត៌មានភាគច្រើន ដែលត្រូវបានសម្លាប់នៅកម្ពុជានាទសវត្សរ៍ចុងក្រោយនេះ»។

ជាការឆ្លើយតបនឹងការលើកឡើងទាំងនេះ អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សុភ័ណ្ឌ បានឱ្យដឹងថា ជាការលើកឡើងដែលពុំមានការពិត និងពុំត្រឹមត្រូវនោះឡើយ។

លោកមានប្រសាសន៍ថា ៖ «អ្នកសារព័ត៌មានអង្គភាពសារព័ត៌មានគ្រប់និន្នាការ និងពហុនិយម អាចបំពេញតួនាទី ភារកិច្ច និងអនុវត្តសេរីភាពរបស់ពួកគេ ដោយសេរីនិងស្មើភាពគ្នា បានគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា និងពុំមានការរើសអើង ឬបំពានសិទ្ធិសេរីភាព ឬគំរាមកំហែង ដូចការលើកឡើងរបស់អង្គការនេះនោះទេ»។

លោកបានបន្តថា ទន្ទឹមនឹងនោះដែរ អង្គភាពសារព័ត៌មាន ក៏ដូចជាអ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា បានបំពេញតួនាទីរបស់ខ្លួនដោយភាពឯករាជ្យដោយសារតែរាល់ការផ្សព្វផ្សាយព័ត៌មានមិនមានការត្រួតពិនិត្យជាមុននោះទេ។ ក្រសួងព័ត៌មានក៏មិនដែលបែងចែកអង្គការភាពសារព័ត៌មានក៏ដូចជាអ្នកសារព័ត៌មានទាំងអស់ថាពួកគាត់ឯករាជ្យឬមិនឯករាជ្យនោះទេ ដោយសារតែសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាគឺបានធានានូវឯកភាពរបស់គាត់ដោយសារការផ្សព្វផ្សាយមិនមានការត្រួតពិនិត្យជាមុននោះទេ។

អ្នកនាំពាក្យរូបនេះបន្តថា ៖ «ប៉ុន្តែជាការកត់សម្គាល់របស់ខ្ញុំវិញ ក្រុមអង្គការសង្គមស៊ីវិល រួមទាំងមជ្ឈមណ្ឌលសិទ្ធិមនុស្សនៅកម្ពុជាបានឱ្យនិយមន័យថា អ្នកសារព័ត៌មានឯករាជ្យទាល់តែអ្នកសារព័ត៌មាននោះផ្សាយព័ត៌មានដែលរិះគន់ទៅលើរាជរដ្ឋាភិបាលកម្ពុជាទើបហៅថា អ្នកសារព័ត៌មានឯករាជ្យ។ ការឱ្យនិយមន័យនេះគឺជាការឱ្យនិយមន័យដែលពុំត្រឹមត្រូវជាការផ្តល់និយមន័យធ្វើឱ្យបែកបាក់សាមគ្គីភាព និងបាត់បង់នូវតម្លៃវិជ្ជាជីវៈសារព័ត៌មានក៏ដូចជាការអនុវត្តសិទ្ធិសេរីភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាយើងផងដែរ»។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជា មានអង្គភាពផ្សព្វផ្សាយ ចំនួន២១០០អង្គភាព និងមានអ្នកសារព័ត៌មានជាតិ និងបរទេស ដែលកំពុងប្រកបវិជ្ជាជីវៈសារព័ត៌មាននៅកម្ពុជា ប្រមាណជិត៦០០០នាក់ ដែលក្នុងមានស្ត្រី ប្រមាណជា៥០០នាក់ផងដែរ។

ទន្ទឹមនឹងនេះដែរ លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានអំពាវនាវដល់គ្រប់ប្រទេសទាំងអស់ឱ្យខិតខំអនុវត្តសេរីភាពសារព័ត៌មាន ឱ្យមានស្តង់ដារតែមួយ ដើម្បីសុខុមាលភាព សេរីភាព សន្តិភាព និងដើម្បីជាជម្រើសប្រកបដោយសេរីភាព ក្នុងការសម្រេចចិត្តរបស់ប្រជាជនគ្រប់រូប។

លោកមានប្រសាសន៍ថា ៖ «ក្រសួងព័ត៌មាន បាននិងកំពុងបន្តគាំទ្រសេរីភាពនៃការបញ្ចេញមតិ ដើម្បីធ្វើយ៉ាងណាឱ្យប្រជាជនកម្ពុជាអាចអនុវត្តសិទ្ធិនេះដោយស្មើភាព និងមិនមានការភ័យខ្លាច ប៉ុន្តែក្រោមគោលការណ៍នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា»៕

# សិស្សសាលាជាង២៧ម៉ឺននាក់ទទួលទានអាហារពេលព្រឹកតាមសាលារៀនឡើងវិញ

*អត្ថបទ៖ អមរិន្ទ ដានុត*

គាំពារសង្គមកម្ពុជា បានឱ្យដឹងថា សិស្សសាលាជាង ២៧ម៉ឺននាក់ នៃសាលាគោលដៅចំនួន១ ១១៣ សាលា ទទួលទានអាហារពេលព្រឹក តាមសាលារៀនឡើងវិញ ដែលអាហារដែលផ្តល់ជូនកុមារទាំងនេះប្រើប្រាស់កសិផលក្នុងសហគមន៍។

សិស្សសាលាទាំងនេះមកពីសាលាគោលដៅចំនួន១ ១១៣ សាលា ដែលតែងតែទទួលទានអាហារនៅសាលារៀន ដែលនេះជាកម្មវិធីផ្តល់អាហារតាមសាលារៀន។

គាំពារសង្គមកម្ពុជា បានលើកឡើងថា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានបើកឱ្យដំណើរការឡើងវិញនូវសាលារៀនទូទាំងប្រទេស, កម្មវិធីផ្តល់អាហារតាមសាលារៀនក៏ត្រលប់មកវិញផងដែរ។ កម្មវិធីនេះបានផ្តល់អាហារក្តៅៗពេលព្រឹកសម្បូរជីវជាតិដល់សិស្សានុសិស្សរហូតដល់ជាង ២៧ម៉ឺននាក់ ជារៀងរាល់ព្រឹក និងបានជួយលើកកម្ពស់កសិផលក្នុងសហគមន៍ ព្រោះបន្លែ និងសាច់សម្រាប់កម្មវិធីនេះ ត្រូវបានផលិតក្នុងសហគមន៍នៅជុំវិញតំបន់គោលដៅនីមួយ។

គាំពារសង្គមកម្ពុជាដែលត្រូវបានដាក់ឱ្យដំណើរការដោយ ក្រុមប្រឹក្សាជាតិគាំពារសង្គម បានបញ្ជាក់ថា ៖ «សិស្សានុសិស្សដែលកំពុងសិក្សាក្នុងសាលាគោលដៅនៅទូទាំងប្រទេសបានបង្ហាញអារម្មណ៍រីករាយបន្ទាប់ពីបានទទួលទានអាហារពេលព្រឹកនៅសាលារៀនឡើងវិញ»។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាផ្តល់ជូនអាហារជារៀងរាល់ព្រឹកដល់សិស្សចំនួន ជាង៥ម៉ឺននាក់ នៅតាមសាលាចំនួន ២៩០ និងសិស្សានុសិស្សចំនួនជាង២២ម៉ឺននាក់នៅតាមសាលាចំនួន ៨២៣ ទៀត ត្រូវបានផ្តល់ជូនដោយកម្មវិធីស្បៀងអាហារពិភពលោក។

លោក ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងឱ្យដឹងថា កម្មវិធីផ្តល់អាហារតាមសាលារៀនគឺជាអាទិភាពមួយរបស់វិស័យអប់រំក្នុងចំណោមកម្មវិធីជំនួយសង្គមជាច្រើនដែលមានចែងនៅក្នុងគោលនយោបាយជាតិស្តីពីការគាំពារសង្គម។

លោកមានប្រសាសន៍ថា ៖ «ក្រសួងអប់រំ យុវជន និងកីឡា ក្នុងនាមជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងជាស្ថាប័នប្រតិបត្តិបានប្តេជ្ញាចិត្តនិងអនុវត្តសម្រេចឱ្យបាននូវវិស្វចនាការនានាដែលមានចែងនៅក្នុងក្របខណ្ឌគោលនយោបាយជាតិស្តីពីការគាំពារសង្គម»។

លោកហង់ជួន ណារ៉ុន បានបន្តថា គោលនយោបាយជាតិក៏រួមមាន ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងកម្មវិធីផ្តល់អាហារតាមសាលារៀនសំដៅធានាធ្វើឱ្យមានលំនឹងប្រាក់ចំណូលរបស់ប្រជាជនស្ថិតនៅក្នុងគ្រួសារក្រីក្រ ងាយរងគ្រោះ និងទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គមប្រកបដោយសមធម៌និងបរិយាបន្ន ពិសេសក្នុងពេលនៃការប្រយុទ្ធប្រឆាំងជាមួយនឹងជំងឺកូវីដ-១៩។

ជាមួយគ្នានេះ ការផ្តល់អាហារតាមសាលារៀនដែលប្រើប្រាស់កសិផលក្នុងសហគមន៍ក៏ជាគោលដៅចំបងមួយនៅក្នុងការផ្តល់និងបង្កើននូវអាហារូបត្ថម្ភដល់កុមារឱ្យទទួលនូវការលូតលាស់រាងកាយមាំមួនបញ្ញាស្មារតី ផ្តោតទៅលើការរៀនសូត្របានល្អប្រសើរ និងជួយបង្កើនសេដ្ឋកិច្ចនៅក្នុងសហគមន៍ឱ្យកាន់តែល្អប្រសើរ តាមរយៈផលិតកម្ម កសិកម្មសុវត្ថិភាពតាមក្រុមគ្រួសារ ស្របទៅនឹងពាក្យថា «សហគមន៍ផ្តល់សុខភាពដល់សាលារៀន សាលារៀននាំមកនូវសុខភាពជូនដល់សហគមន៍»។ នេះបើតាមការបញ្ជាក់បន្ថែមរបស់លោក ហង់ជួន ណារ៉ុន៕

# ប្រមុខរាជរដ្ឋាភិបាលបានដកកាតព្វកិច្ចពាក់ម៉ាសនៅទីសាធារណៈ ខណៈប្រជាពលរដ្ឋមួយចំនួនធំនៅបន្តអនុវត្ត

*អត្ថបទ: ផល សុផានិត*

កាតព្វកិច្ចពាក់ម៉ាសនៅទីសាធារណៈនិងទីតាំងលំហរ ត្រូវបានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តេចប្រកាសដកចេញ ដែលជាការសាទរថ្មីទៅនឹងការជោគជ័យមួយដ៏ធំក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩នៅក្នុងប្រទេសកម្ពុជា។

ប្រជាពលរដ្ឋមានការសប្បាយចិត្តចំពោះការលើកលែងកាតព្វកិច្ចពាក់ម៉ាសនេះ ខណៈពេលដែលប្រជាពលរដ្ឋមួយចំនួនធំនៅតែបន្តពាក់ម៉ាស ជាពិសេសមនុស្សវ័យចំណាស់ និងកុមារតូចៗ ដើម្បីបន្តរក្សាសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ បើទោះបីជាអត្រានៃការរកឃើញអ្នកឆ្លងមេរោគកូវីដ-១៩មានចំនួនតែមួយខ្ទង់ក៏ដោយ។

កត្តារក្សាអនាម័យជារឿងសំខាន់ គួរកត់សម្គាល់ដែរថា នៅតាមទីសាធារណៈមួយចំនួនធំនៅរាជធានីភ្នំពេញ ជាពិសេសនៅសួនច្បារវិមានឯករាជ្យ នៅតែមានការបន្តរក្សាការពាក់ម៉ាសការពារបានត្រឹមត្រូវដដែលជាប្រចាំ។ ប្រជាពលរដ្ឋដែលបានបន្តការពាក់ម៉ាសដដែល ក៏បានសំណូមពរដល់ប្រជាពលរដ្ឋផ្សេងទៀតសូមបន្តអនុវត្តនូវវិធានការការពារជាចាំបាច់ ទោះបីជាប្រទេសកម្ពុជាបានធូរស្រាលពីការចម្លងមេរោគកូវីដ-១៩យ៉ាងណាក៏ដោយ។

លោក សួន ឡាត់ ជាប្រជាពលរដ្ឋរស់នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន បានថ្លែងថា ៖ «ខ្ញុំចាប់អារម្មណ៍តែពីការការពារខ្លួនខ្ញុំតែប៉ុណ្ណោះ និងក្រុមគ្រួសារខ្ញុំ។ ខ្ញុំខ្លាចកូវីដ១៩ណឹងហើយ បានខ្ញុំបន្តពាក់ម៉ាស។ យើងត្រូវបន្តការពារខ្លួនអោយល្អបែបនេះបន្តទៀត ដើម្បីយើងអាចជៀសផុតពីជំងឺនេះឆាប់ៗនៅក្នុងប្រទេសកម្ពុជា»។

បុរសវ័យជិត៧០ឆ្នាំ រូបនេះបានបន្តថា ប្រជាពលរដ្ឋកម្ពុជាកុំភ្លេចបន្តរក្សាអនាម័យ និងបន្តចូលរួមចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល ឱ្យបានគ្រប់ចំនួនដូសកំណត់ ព្រមទាំងបន្តធ្វើតេស្តរកមេរោគកូវីដ-១៩នៅពេលដែល មានការសង្ស័យណាមួយ។

ចំណែក លោកស្រី នួន សុម៉ាលី ប្រជាពលរដ្ឋម្នាក់ទៀត បានប្រាប់ថា ៖ «យើងត្រូវចូលរួមបន្តថែរក្សាអនាម័យខ្លួនប្រាណយើង លាងសម្អាតដៃជាមួយអាល់កុល ជេល សាប៊ូដដែល ធ្វើយ៉ាងណាដើម្បីឱ្យមានអនាម័យរៀងៗខ្លួន។ យើងត្រូវការពារខ្លួនយើងរៀងៗខ្លួន ដែលធ្វើឱ្យយើងជៀសផុតពីជំងឺកូវីដ-១៩នេះ»។

រយៈពេលពីរឆ្នាំនៃការរស់នៅជាមួយមេរោគកូវីដ-១៩ ប្រជាពលរដ្ឋកម្ពុជាហាក់យល់ដឹងច្រើនពីវិធានការ ការពារ ប៉ុន្តែក៏នៅតែមានប្រជាពលរដ្ឋមួយចំនួនតូចមិនទាន់សម្របខ្លួនបានល្អប្រសើរ ជាមួយនឹងការរស់នៅក្នុងបរិបទថ្មីនៅឡើយនោះទេ។

ក្នុងសារពិសេសជាសំឡេងកាលពីថ្ងៃទី២៦ ខែមេសា កន្លងទៅនេះ សម្តេចតេជោបានលើកឡើងដោយលោកសង្ឃឹមថា ការដកម៉ាសចេញនឹងបង្កើតបរិយាកាសសប្បាយរីករាយសម្រាប់បងប្អូនប្រជាពលរដ្ឋ ហើយក៏នឹងចូលរួមចំណែកទៅលើការសន្សំសំចៃក្នុងការប្រើប្រាស់ ដោយផ្ទេរការចំណាយពីការទិញម៉ាសមកពាក់បង្វែរទៅជាការទិញម្ហូបអាហារ ទិញសម្លៀកបំពាក់ឱ្យកូនចៅ និងទុកសន្សំប្រាក់កាសនោះ ដើម្បីប្រើប្រាស់ទៅលើគោលដៅផ្សេង។

ប៉ុន្តែសម្តេចតេជោ ក៏នូវតែអំពាវនាវឱ្យរក្សាទុកម៉ាស់ជាប់និងខ្លួន នៅពេលដែលចូលដល់កន្លែងដែលចាំបាច់ត្រូវមានមនុស្សកុះករឬសង្ស័យថាអាចមានករណីមេរោគកូវីដ-១៩៕

# ស្វាយរៀងក្លាយជាខេត្តដំបូងគេនៅកម្ពុជា បញ្ចប់ការបន្ទោបង់ពាសវាលពាសកាលទាំងស្រុង

*អត្ថបទ៖ អមរិន្ទ ដានុត*

ខេត្តស្វាយរៀងបានទទួលជយលាភីលេខ១ ដែលជាខេត្តទី១ បញ្ចប់ការបន្ទោបង់ពាសវាលពាសកាលទាំងស្រុង (ODF) ១០០ភាគរយ ដំបូងគេនៅកម្ពុជា ក្នុងចំណោម ២៥ រាជធានីខេត្ត ដែលគ្រប់ខ្នងផ្ទះ មានបង្គន់អនាម័យប្រើប្រាស់ នៅឆ្នាំ២០២២នេះ។

កម្មវិធីប្រកាសបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលទាំងស្រុងនេះ ត្រូវបានធ្វើឡើង កាលពីថ្ងៃទី២៧ ខែមេសា ក្រោមអធិបតីភាពលោក អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃខេត្ត តំណាងអង្គការដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋជាច្រើននាក់។



លោកម៉ែនវិបុលអភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង បានថ្លែងនាឱកាសនោះថា លទ្ធផលដ៏ឧដុង្គឧត្តមដែលទទួលបាននៅពេលនេះ គឺបានឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រជាតិ (PSP) និងផែនការសកម្មភាពជាតិ (NSP) ស្តីពីការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រកបដោយចរភាព (SGDs) ដើម្បីរួមចំណែកកាត់បន្ថយភាពក្រក្រីរបស់ប្រជាពលរដ្ឋ។

លោកមានប្រសាសន៍ថា ៖ «លទ្ធផលដ៏ល្អប្រសើរនេះមិនត្រឹមតែបង្ហាញឱ្យឃើញការរីកចម្រើនផ្នត់គំនិតរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងបញ្ហាសុខភាព និងអនាម័យប៉ុណ្ណោះទេ ប៉ុន្តែបានឆ្លុះបញ្ចាំងពីការអភិវឌ្ឍនិងជីវភាពរបស់នៅល្អប្រសើររបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមវិភាគទាន និងម្ចាស់ការក្នុងការសាងសង់បង្គន់អនាម័យប្រើប្រាស់នៅតាមខ្នងផ្ទះ និងសហគមន៍»។

បើតាមលោក ម៉ែន វិបុល ការងារលើកកម្ពស់អនាម័យខេត្តទទួលបានភាពជោគជ័យនាពេលនេះ រដ្ឋបាលខេត្តស្វាយរៀងបានបង្កើតក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ថ្នាក់ខេត្ត (PWG-RWSSH) ដែលមានលោក តូច ប៉ូលីវ៉ា អភិបាលរងខេត្ត ជាប្រធានក្រុមការងារនេះ។

យោងតាមរបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩-២០២០ បានឲ្យដឹងថា ឆ្នាំ២០២២ អត្រាប្រជាជនមានប្រភពទឹក កែលម្អប្រើប្រាស់មាន៨០% ចំណែកឯអត្រាប្រជាជនមានបង្គន់អនាម័យកែលម្អប្រើប្រាស់មាន ៨០% និងគ្រួសារប្រមាណ ៨៩% ប្រើប្រាស់ឧបករណ៍ផ្សេងៗ សម្រាប់លាងសម្អាតដៃនៅក្នុងបរិវេណផ្ទះ។

លោក អ៊ុក រ៉ាប៊ុន បានលើកឡើងផងដែរថា រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាពជាតិ និងផែនការសកម្មភាពខេត្ត ដើម្បីសម្រេចឲ្យបាន គោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពគឺ នៅឆ្នាំ២០២៥ ប្រជាពលរដ្ឋគ្រប់រូប នៅតាមសហគមន៍ជនបទ មានលទ្ធភាពទទួលសេវាផ្គត់ផ្គង់ទឹកស្អាត និងការរស់នៅ ក្នុងបរិស្ថាន ដែលមានអនាម័យល្អប្រកបដោយនិរន្តរភាព។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ ក្រសួងក្រសួងអភិវឌ្ឍន៍ជនបទ បាននិងកំពុងបន្តអនុវត្តនូវផែនការ យុទ្ធសាស្ត្រជាតិស្តីពី ការផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទ ឆ្នាំ២០១៤-២០២៥ និងផែនការសកម្មភាពជាតិជំហានទី២ ស្តីពី ការផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទឆ្នាំ ២០១៩-២០២៣ ស្របតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល។

ក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់យកខេត្តគោលដៅចំនួន៥ គឺខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកែប ខេត្តព្រៃវែង និងខេត្តកណ្តាល ឲ្យក្លាយជាខេត្ត ដែលបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលនៅឆ្នាំ២០២៣ ។

គួរបញ្ជាក់ផងដែរថា រដ្ឋបាលខេត្តស្វាយរៀង បានប្តេជ្ញាលើកកម្ពស់ការងារលើកកម្ពស់អនាម័យជនបទ និងការងារបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលទាំងស្រុង (ODF) ឱ្យក្លាយជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលទាំងស្រុងល្អប្រសើរ (ODF+) តាមផែនការដែលបានគ្រោងទុក ។

ខេត្តស្វាយរៀង ស្ថិតនៅទិសអាគ្នេយ៍នៃរាជធានីភ្នំពេញ មានចម្ងាយប្រមាណ ១២៥គ.ម មានព្រំប្រទល់ខាងលិចនិងខាងជើងទល់នឹងខេត្តព្រៃវែង ខាងកើតនិងខាងត្បូងទល់នឹងខេត្តតៃនិញ នឹងខេត្តឡុងអាន ប្រទេសវៀតណាម។

ប្រជាជនបច្ចុប្បន្នមានចំនួនជាង ៦០ម៉ឺននាក់ ផ្ទៃដីសរុបទូទាំងខេត្ត មាន ២.៩៦៦,៤០ គ.ម២ បែងចែកជា ០២ក្រុង (ក្រុងស្វាយរៀង និងក្រុងបាវិត) និង ០៦ស្រុក (ស្រុកស្វាយជ្រំ ស្រុករមាសហែក ស្រុករំដួល ស្រុកស្វាយទាប ស្រុកកំពង់រោទិ៍ និងស្រុកចន្ទ្រា) បែកចេញជា ១២សង្កាត់ និង៦៨ឃុំ (៨០ ឃុំ-សង្កាត់) ស្មើនឹង ៦៩០ភូមិ ៕

# អាជីវកម្មទឹកឃ្មុំមណ្ឌលគិរី កើនឡើង ក្រោយចុះបញ្ជី ម៉ាកសម្គាល់ភូមិសាស្ត្រ





*អត្ថបទ៖ ផល សុផានិត*

ក្រោយពីទទួលបានការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនៃទឹកឃ្មុំមណ្ឌលគិរី កាលពីពេលថ្មីៗនេះ ប្រជាកសិករកាន់តែទទួលបានផលកម្រៃខ្ពស់ និងបន្ថែមការស្វះស្វែងប្រមូលផលជាងមុន។

នៅក្នុងពិធីតាំងពិព័ណ៌ភូមិមួយផលិតផលមួយ លោក ស្រ៊ីវ សុវណ្ណនី ប្រធានសមាគមអភិរក្សឃ្មុំព្រៃខេត្តមណ្ឌលគិរី បានអោយដឹងថា បច្ចុប្បន្នទឹកឃ្មុំព្រៃមណ្ឌលគិរី បែងចែកតម្លៃលក់ជា៣ប្រភេទ ក្នុងនោះចំណុះ ២៥០ក្រាម តម្លៃ៧ដុល្លារ, ចំណុះ៤៥០ក្រាម តម្លៃ១៣ដុល្លារ និងចំណុះ៥០០ក្រាម តម្លៃ ១៤ដុល្លារ ក្នុងមួយដប/កែវ។

លោកបន្តថា ឆ្នាំនេះការប្រមូលផលទឹកឃ្មុំព្រៃមណ្ឌលគិរី បានប្រមាណ ១០០តោន។ ក្នុង១ឆ្នាំ ការប្រមូលផលទឹកឃ្មុំសុទ្ធ គឺមានចំនួនតែ១ដងប៉ុណ្ណោះ គឺចាប់ពីខែមីនា ដល់ខែមិថុនា ខណៈចាប់ពីខែមិថុនាទៅ គឺជាប្រភេទទឹកឃ្មុំ ខែវស្សា ដែលមានជាតិទឹកច្រើន។ ការប្រមូល និងផលិតទឹកឃ្មុំព្រៃមណ្ឌលគិរី ត្រូវបានធ្វើឡើងដោយសហគមន៍ចំនួន១១ ក្នុងខេត្តមណ្ឌលគិរី ដែលមានសមាជិកប្រមាណជាង ២ពាន់គ្រួសារ។

លោក បន្ថែមថា ការចុះបញ្ជីការពារម៉ាកជាសម្គាល់ភូមិសាស្ត្រទំនិញនៅកម្ពុជារួចមក បានធ្វើឲ្យកសិករ ដែលសមាជិកនេះ គាត់មានទំនុកចិត្តក្នុងការប្រមូលផលថែមទៀត ជាពិសេសនោះ គឺតម្លៃមានការកើនខ្ពស់បន្តិច ធ្វើឲ្យពួកគាត់មានជីវភាពល្អប្រសើរមួយកម្រិតទៀត បន្ទាប់ការងារកសិកម្មមួយចំនួនផ្សេងទៀតរបស់គាត់ ដូចជាការដាំដុះដំឡូង និងការធ្វើស្រែជាដើម។

«ទឹកឃ្មុំព្រៃមណ្ឌលគិរី» ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (GI) ក្នុងគោលដៅផ្ដល់កិច្ចការពារកម្មសិទ្ធិបញ្ញា លើកកម្ពស់គុណភាពសម្បកវេចខ្ចប់ និងកេរ្ដិ៍ឈ្មោះ ព្រមទាំងបង្កើនចង្វាក់តម្លៃ បង្កើតការងារ និងលើកកម្ពស់ជីវភាពប្រជាជន។

ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» បានរៀបចំឡើង នៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លោក ប៉ាន សូរស័ក្តិ បានថ្លែងថា ក្រសួងពាណិជ្ជកម្ម នឹងបន្តសហការជាមួយអាជ្ញាធរមូលដ្ឋានក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអភិវឌ្ឍម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» ឱ្យក្លាយជាគោលដៅទេសចរណ៍ តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធសមាគមអភិរក្សឃ្មុំព្រៃមណ្ឌលគិរី មូលដ្ឋានផលិតកម្ម និងទីកន្លែងប្រមូលផលទឹកឃ្មុំ ដើម្បីទាក់ទាញទេសចរ ស្របតាមផែនការមេស្ដីពីការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ ២០២១-២០៣៥ របស់រាជរដ្ឋាភិបាល។

ការថែរក្សា និងធានាបាននូវកេរ្ដិ៍ឈ្មោះ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» និងការទាញអត្ថប្រយោជន៍ពីការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ គឺពិតណាស់អាស្រ័យលើការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗនៅក្នុងសហគមន៍ដែលចាំបាច់ត្រូវមានសាមគ្គីភាព ភាពស្មោះត្រង់ សុចរិត និងអភិបាលកិច្ចគ្រប់គ្រងល្អ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ទើបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» ផ្ដល់នូវគុណតម្លៃពិតប្រាកដ ព្រមទាំងធានានូវនិរន្តរភាពសម្រាប់អ្នកជំនាន់ក្រោយ។

លោកបានបញ្ជាក់ថា៖ «ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» មិនត្រឹមតែជាអត្តសញ្ញាណផលិតផលរបស់សមាគមអភិរក្សឃ្មុំព្រៃខេត្តមណ្ឌលគិរីតែមួយប៉ុណ្ណោះទេ ប៉ុន្តែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះនឹងក្លាយជាផ្នែកនៃការផ្សព្វផ្សាយកេរ្ដិ៍ឈ្មោះ និងវប្បធម៌ប្រពៃណីរបស់ប្រជាជនកម្ពុជាផងដែរ»៕

# ទីផ្សារទេសចរណ៍បរទេសនៅកម្ពុជាចាប់ផ្ដើមកម្រើកហើយ





*អត្ថបទ៖ អរិយបុត្រ*

គ្រឹះស្ថានអង្គរបានឱ្យដឹងថាកម្ពុជា ទទួលបានចំណូលជាង ១,៣លានដុល្លារ ពីការលក់សំបុត្រចូលទស្សនាអង្គរ ក្នុងរយៈពេល៤ខែ ឆ្នាំ២០២២ ដោយ ចំនួននេះ កើនឡើងជាង ៦៦២ភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២ ។

គ្រឹះស្ថានអង្គរបញ្ជាក់ថា ក្នុងរយៈពេល ៤ខែមកនេះ មានទេសចរសរុប ៣៣.២០៥នាក់ បានទិញសំបុត្រចូលរមណីយដ្ឋានអង្គរ ដែលចំនួននេះកើនជាង ៦៣៣ភាគរយ ធៀបនឹងរយៈពេលក្នុងឆ្នាំ២០២១ គ្រាដែលកម្ពុជា ក៏ដូចជាពិភពលោកជួបវិបត្តិធ្ងន់ធ្ងរពីការរាតត្បាតនៃជំងឺកូវីដ-១៩ ។ ដោយឡែក ក្នុងខែមេសាកន្លងទៅនេះ មានទេសចរ ចំនួន ១៣.៣៦៤នាក់ បានទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ហើយចំណូលលក់សំបុត្រនោះមានចំនួន ៥៣៧.០៤០ដុល្លារ។

ក្រៅពីនេះតំបន់អង្គរ គ្រឹះស្ថានអង្គរ ក៏បានលក់សំបុត្រចូលទស្សនាតំបន់កោះកេរបាន ចំនួន ៣.៤៣៥ដុល្លារដែរ ដល់ទេសចរអន្តរជាតិចំនួន ២២៩នាក់ ក្នុងខែមេសាកន្លងទៅ។ ទន្ទឹមនឹងនេះ ចំណូលពីការលក់សំបុត្រទូក នៅកំពង់ផែចុងឃ្លៀស ក្នុងខែមេសា មានចំនួន ១៥.៩១៩ដុល្លារទៅដល់ទេសចរចំនួន ៣.៨១៧នាក់ផងដែរ។

រហូតមកដល់ពេលនេះ ពលរដ្ឋកម្ពុជានៅតែបន្តទទួលសិទ្ធិធ្វើដំណើរទេសចរនិងរីករាយកំសាន្តតាមរមណីដ្ឋាននានាដែលជាសម្បត្តិបេតិកភ័ណ្ឌជាតិ ដោយមិនគិតថ្លៃ ប៉ុន្តែភ្ញៀវទេសចរបរទេសត្រូវទិញសំបុត្រចូលទស្សនា ។

យោងតាមស្ថិតិរបស់ក្រសួងទេសចរណ៍បានឲ្យដឹងថា នៅក្នុងរយៈពេល ៣ ខែ ដើមឆ្នាំ ២០២២ នេះ កម្ពុជាបានទទួលភ្ញៀវទេសចរបរទេសសរុបចំនួន ១៥៩.៥៤៦ នាក់ កើនឡើង ១២៥ ភាគរយ ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំ ២០២១ កន្លងទៅ ។

ប្រភពដដែលបានបន្តថា ភ្ញៀវទេសចរបរទេសដែលចូលមកកម្ពុជាច្រើនជាងគេ គឺវៀតណាម ថៃ ចិន និង អាមេរិក ដោយវៀតណាមមាន ៤៦.៣០៣ នាក់ ថៃ មាន ៣៩.៦១៥ នាក់ ចិន ចំនួន ៩.៧៥៣ នាក់ និង អាមេរិក ប្រមាណជា ៨.៨២០ នាក់ ។ បណ្ដាភ្ញៀវទេសចរ ទាំងនេះ សុទ្ធតែមានកំណើន ដោយនៅក្នុងនោះ ភ្ញៀវទេសចរវៀតណាមកើន ដល់ទៅ ២៩ ភាគរយ ថៃ កើន ជិត ២៥ ភាគរយ ចិន កើន តែ ៦ ភាគរយ ហើយអាមេរិក កើន ៥,៥ ភាគរយ៕

# កម្ពុជាកំពុងតែជំរុញកិច្ចការចុះបញ្ជីនិងលើកកំពស់ការគោរពកម្មសិទ្ធិបញ្ញា

*អត្ថបទ៖ អរិយបុត្រ*

កម្ពុជាកំពុងតែប្តេជ្ញាចិត្តនៅក្នុងការជំរុញនិងលើកទឹកចិត្តការចុះបញ្ជីនិងលើកកំពស់ការគោរពកម្មសិទ្ធិបញ្ញា ដើម្បីជំរុញការប្រកួតប្រជែងដោយស្មើភាពនិងតម្លាភាពនៅទីផ្សារពាណិជ្ជកម្មក្នុងស្រុក តំបន់ និង ពិភពលោក។



លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានថ្លែងកាលពីពេលថ្មីៗកន្លងទៅនេះថា នាឆ្នាំកន្លងមក គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានខិតខំបំពេញកិច្ចការរបស់ខ្លួនបានយ៉ាងល្អ និងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន រួមមានការចុះបញ្ជីកម្មសិទ្ធិបញ្ញា ជាពិសេសការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាពទាំងនៅកម្ពុជា និងបណ្តាប្រទេសសំខាន់។

លោកបានបន្តទៀតថា ការចូលជាសមាជិកនៃកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ, ការរៀបចំសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា, កិច្ចសហប្រតិបត្តិការអន្តរជាតិតាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គភាពកម្មសិទ្ធិបញ្ញាមួយចំនួន និងការងារអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ, ការងារលើកកម្ពស់ចំណេះដឹងសាធារណៈ និងការផ្សព្វផ្សាយច្បាប់ និងទទួលជោគជ័យក្នុងការបង្ក្រាប និងទប់ស្កាត់បទល្មើសកម្មសិទ្ធិបញ្ញាដែលមានលទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់។

លោករដ្ឋមន្ត្រីបញ្ជាក់ថា កម្មសិទ្ធិបញ្ញាជាឧបករណ៍ដ៏សំខាន់មួយសម្រាប់កម្ពុជា ដើម្បីកសាងកេរ្តិ៍ឈ្មោះម៉ាកផលិតផលសក្តានុពល និងលើកកម្ពស់ចំណេះដឹងអំពីកម្មសិទ្ធិបញ្ញាឲ្យក្លាយទៅជាកម្លាំងចលករក្នុងការអភិវឌ្ឍ សេដ្ឋកិច្ចពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ ទេសចរណ៍ និងកសិកម្ម តាមរយៈការលើកកម្ពស់ កិច្ចការពារកម្មសិទ្ធិបញ្ញា កេរ្តិ៍ឈ្មោះម៉ាក និងផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា។

ការបង្កើតស្នាដៃវប្បធម៌ តក្កកម្ម ធនធានពន្ធចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងការបង្កើតផលិតផលបច្ចេកវិទ្យា និងជំរុញគំនិតច្នៃប្រឌិត និងការបង្កើតថ្មី ព្រមទាំងឧស្សាហកម្មវប្បធម៌ ឱ្យឆ្លើយតបទៅនឹងបរិបទសេដ្ឋកិច្ច-សង្គមឌីជីថល និងបដិវត្តឧស្សាហកម្មជំនាន់ទី៤ ហើយចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០៥០ និងជាមូលដ្ឋានកសាងបរិយាកាសវិនិយោគប្រកបដោយទំនុកចិត្ត និងសង្គមដែលពោរពេញនវានុវត្តភាព។

លោកបានថ្លែងថា ៖ «ដើម្បីលើកម្ពស់វិស័យកម្មសិទ្ធិបញ្ញាក្រសួងពាណិជ្ជកម្មបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកសាងសមត្ថភាពសហគ្រាសធុនតូច និងមធ្យមឱ្យប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងគោលបំណងអភិវឌ្ឍសហគ្រាសទាំងនោះតាមរយៈគម្រោងកសាងកេរ្តិ៍ឈ្មោះម៉ាក ព្រមទាំងបានចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសក្តានុពលជាច្រើន»។

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសក្តានុពលទាំងនោះមានដូចជា ម្រេចកំពត ស្ករត្នោតកំពង់ស្ពឺ ក្រូចថ្លុងកោះទ្រង់ ទឹកឃ្មុំព្រៃមណ្ឌលគិរី និងគ្រោងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបន្ថែមទៀត ដូចជា អំបិល និងផ្កាអំបិលកំពត កែបបង្កងតាកែវ និង ទឹកត្រីកំពត។

លោកបានបន្តថា ក្រៅពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្រសួងពាណិជ្ជកម្មបានចុះបញ្ជីម៉ាកសមូហភាពគុយទាវភ្នំពេញ អំបុកកំពង់ធំ អង្ករព្រះវិហារ និងគ្រោងចុះបញ្ជីបន្ថែមទៀតនូវម៉ាកសមូហភាពដូចជា៖ ចម្លាក់ប្រាក់ស្លាន់ខេត្តកណ្តាល ក្រូចពោធិ៍សាត់ នំបញ្ចុកសៀមរាប និង ដូងខ្ទិះបាត់ដំបង។




សមិទ្ធផលទាំងនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាកំណើនសេដ្ឋកិច្ច ពង្រឹងអភិបាលកិច្ចល្អ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា ។

លោកស្រី ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានមានប្រសាសន៍ថា៖ «កម្មសិទ្ធិបញ្ញាសំខាន់ណាស់ ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ទាក់ទាញការវិនិយោគ និងបង្កើនការបង្កើតស្នាដៃថ្មីៗជាដើម»។



លោកស្រីរដ្ឋមន្ត្រីបញ្ជាក់ថា កម្មសិទ្ធិបញ្ញាវាជាឧករណ៍ការពារការបង្កើតផលិតផលបច្ចេកវិទ្យា និងជំរុញគំនិតច្នៃប្រឌិត ក៏ដូចជាការបង្កើតថ្មី ព្រមទាំងឧស្សាហកម្មវប្បធម៌ឱ្យឆ្លើយតបទៅនឹងបរិបទសេដ្ឋកិច្ច និងសង្គមឌីជីថល និងបដិវត្តឧស្សាហកម្មជំនាន់ទី៤ ហើយចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០៥០ ។

លោកស្រីបានបន្ថែមថា ជាក់ស្តែងច្បាប់សិទ្ធិអ្នកនិពន្ធក៏ជាផ្នែកមួយនៃច្បាប់កម្មសិទ្ធិបញ្ញា ត្រូវបានបង្កើតឡើងក្នុងគោលបំណង និងគោលដៅជួយជំរុញការបង្កើតឱ្យមានស្នាដៃថ្មីៗ និងការពារនូវផលិតផលវប្បធម៌ជាស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាម និងអង្គភាពទូរផ្សាយសំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវស្របច្បាប់លើផលិតផលវប្បធម៌ទាំងនោះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យវប្បធម៌ និងស្របតាមគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ឆ្នាំ២០១៤ និងចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម៕

# ហ្វីលីពីនប្រកាសបើកកម្មវិធីជដែកដេញដោលយុវជនអាស៊ានឆ្នាំ ២០២២

*អត្ថបទ៖ អរិយបុត្រ*

ជាផ្នែកមួយនៃគោលដៅរបស់ខ្លួនក្នុងការលើកកម្ពស់ការយល់ដឹងរបស់យុវជន និងរៀបចំដំណើរការបង្កើតគោលនយោបាយរបស់ពួកគេទាក់ទងនឹងតំបន់អាស៊ីអគ្នេយ៍ឬអាស៊ាន គណៈកម្មាធិការយុវជនជាតិហ្វីលីពីនបានបើកកម្មវិធី ការជដែកដេញដោលអំពីយុវជនអាស៊ានឆ្នាំ ២០២២ ។

កម្មវិធីប្រកួតប្រជែង ការជដែកដេញដោលអំពីអាស៊ាននេះគ្រោងនឹងរៀបចំធ្វើឡើងចាប់ពីខែមិថុនា រហូតដល់ខែតុលា ឆ្នាំ២០២២ នៅក្រោមគំនិតផ្តួចផ្តើមរបស់គណៈកម្មាធិការយុវជនជាតិហ្វីលីពីន រួមជាមួយអាស៊ាននិងក្រសួងអប់រំ យុវជន និងកីឡា។

គណៈកម្មាធិការយុវជនជាតិហ្វីលីពីន បានប្រកាសថា ៖ «កម្មវិធីប្រកួតប្រជែងការជដែកដេញដោលអំពីយុវជនអាស៊ានឆ្នាំ ២០២២» នេះមានគោលបំណងគ្រាន់តែបង្កើនសន្ទុះក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់អាស៊ាន តាមរយៈការលើកកម្ពស់ការយល់ដឹងរបស់យុវជន ការរៀបចំដំណើរការបង្កើតគោលនយោបាយ និងការពង្រឹងការធ្វើឱ្យទំនាក់ទំនងរវាងប្រជាជននិងប្រជាជនកាន់តែស៊ីជម្រៅបន្ថែមទៀតសម្រាប់យុវជននិងយុវនារីនៅក្នុងតំបន់ ដែលពួកគេនឹងបន្តវេនដឹកនាំសង្គមបន្ត។

គណៈកម្មាធិការនេះបានអះអាងថា ខ្លួននឹងជ្រើសរើសក្រុមជដែកដេញដោលចំនួន៣ ដែលរួមមានគ្រូបង្វឹកម្នាក់ និងអ្នកជដែកដេញដោលចំនួន ៥ នាក់ក្នុងមួយក្រុម ព្រមទាំងបុគ្គលម្នាក់ដើម្បីបង្កើតក្រុមជម្រើសជាតិ សម្រាប់ប្រកួត។

ទន្ទឹមនឹងនេះ អ្នកដាក់ពាក្យត្រូវតែជាពលរដ្ឋហ្វីលីពីនដែលមានអាយុពី ១៨ ទៅ ៣៥ ឆ្នាំ ដែលជាអាយុកំណត់សម្រាប់យុវជន ដោយពួកគេត្រូវតែចេះសរសេរ និងនិយាយភាសាអង់គ្លេសបានល្អ។

ជាទូទៅកម្មវិធីនេះមិនមែនរៀបចំឡើងតែនៅក្នុងប្រទេសហ្វីលីពិននោះទេ កន្លងមកកម្មវិធីនេះត្រូវបានរៀបចំនៅតាមប្រទេសនានានៅក្នុងតំបន់ ដោយរួមទាំងកម្ពុជាផងដែរ សំដៅគឺចូលរួមនិងជំរុញយុវជននៅក្នុងតំបន់បង្កើនការស្វែងយល់អំពីអាស៊ានឲ្យកាន់តែទូលំទូលាយនិងស៊ីជម្រៅ ខណៈដែលពេលនេះ អាស៊ានកំពុងតែមានផែនការធ្វើយ៉ាងណាឲ្យតំបន់ទាំងមូល ក្លាយជា តំបន់មួយដ៏មានសក្តានុពល ទាំងសេដ្ឋកិច្ចនិងនយោបាយ ។

ក្នុងនាមជាប្រធានអាស៊ានឆ្នាំ ២០២២ កម្ពុជាប្តេជ្ញាចិត្តដឹកនាំអាស៊ានបោះជំហានទៅមុខក្រោមមូលបទ «អាស៊ានរួមគ្នាធ្វើ - ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា (ASEAN A.C.T.: Addressing Challenges Together)» ដើម្បីភាពសុខដុមរមនា សន្តិភាព និងវិបុលភាពក្នុងតំបន់ទាំងមូល ខណៈដែលថ្មីៗកន្លងទៅនេះ អាស៊ានបានប្រកាសឆ្នាំ ២០២២ ជាឆ្នាំយុវជនអាស៊ាន។

ឆ្នាំយុវជនអាស៊ាននឹងនៅតែស្របតាមចក្ខុវិស័យក្រោយឆ្នាំ ២០២០ នៃការអភិវឌ្ឍយុវជនអាស៊ាន ដោយផ្តោតលើការជំរុញពហុជំនាញ ជាពិសេសគឺជំនាញឌីជីថលក្នុងសតវត្សរ៍ទី ២១ និងការរៀបចំស្ថាប័ននៃយន្តការចូលរួមរបស់យុវជន ក្រោមផែនការការងារអាស៊ាន ២០២១-២០២៥ ។




ស្របពេលដែលឆ្នាំនេះ អាស៊ានបានប្រកាសជាឆ្នាំយុវជនអាស៊ាន យ៉ាងហោចណាស់អាស៊ានគ្រោងរៀបចំសកម្មភាពចំនួន៤ ដែលរួមមានកម្មវិធីសន្ទនាយុវជនអាស៊ានលើកទី១ ដែលផ្តល់មូលនិធិដោយសាធារណរដ្ឋកូរ៉េ, ការប្រលងវីដេអូយុវជនអាស៊ានលើកទី៦ ក្រោមកិច្ចសហការជាមួយមូលនិធិអាស៊ាន និង US PROSPECT, ការប្រកួតរូបថតយុវជនអាស៊ាន និងការរៀបចំកម្មវិធីជដែកដេញដោលយុវជនអាស៊ាន ឆ្នាំ២០២២៕

NATIONAL YOUTH COMMISSION
OFFICE OF THE PRESIDENT



# កម្ពុជាកំពុងឈានទៅរកការសម្រេច ការលុបបំបាត់ជំងឺគ្រុនចាញ់ តាមផែនការក្នុងឆ្នាំ២០២៥ ខណៈ៤ឆ្នាំចុងក្រោយ គ្មានអ្នកស្លាប់ដោយជំងឺនេះ

*អត្ថបទ៖ អមរិន្ទ ដានុត*

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងដាក់ចេញនូវផែនការជាច្រើន រាប់ទាំងផែនការបំបាត់ជំងឺគ្រុនចាញ់ឱ្យបាននៅឆ្នាំ២០២៥ ខណៈដែលក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាគ្មានករណីស្លាប់ដោយជំងឺគ្រុនចាញ់ឡើយ បើទោះជាព្រះរាជាណាចក្រមួយនេះប្រឈមខ្លាំងនឹងជំងឺកូវីដ-១៩ ក៏ដោយ។



យោងរបាយការណ៍របស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានបង្ហាញថា ប្រទេសកម្ពុជាធ្លាប់មានករណីឈឺដោយជំងឺគ្រុនចាញ់រហូតជាង១៧ ម៉ឺនករណី នាទសវត្សរ៍ឆ្នាំ៨០ និងស្លាប់ជិត ១ ០០០នាក់ ប៉ុន្តែចាប់ពីឆ្នាំ២០១៨ ករណីស្លាប់ដោយសារជំងឺគ្រុនចាញ់លែងមានរហូតមកដល់បច្ចុប្បន្ននេះ បានន័យថា កម្ពុជាសម្រេចបានជោគជ័យមុនគោលដៅគ្រោងទុកឆ្នាំ២០២០ ។

របាយការណ៍ដដែលបានបន្តថា ឆ្នាំ២០២១ ជំងឺគ្រុនចាញ់សរុបមាន ៤ ២៧៩ករណីឈឺ ដែលចំនួនករណី បានបន្ថយចុះ៥៤% បើប្រៀបធៀបនឹងឆ្នាំ២០២០ ដែលមាន ៩ ២៣៤ករណី។ ចំពោះជំងឺគ្រុនចាញ់ ទម្រង់សន្ធំនិងចម្រុះមាន ៣២០ករណី ក្នុងឆ្នាំ២០២១ គឺបានបន្ថយចុះ៦៥% បើប្រៀបធៀបនឹងឆ្នាំ២០២០ មាន ៩៣៦ករណីឈឺ។

ប្រភពដដែលបានបន្តថា ចំពោះករណីគ្រុនចាញ់ប្រភេទវីវ៉ាក់ក៏មានការថយចុះ៥២% ពីចំនួន ៨ ២៩៨ នៅ ឆ្នាំ២០២០ មកនៅចំនួន ៣ ៩៥៩ករណី នៅឆ្នាំ២០២១ ។

ទាក់ទងនឹងអត្រានៃការថយចុះទាំងករណីឈឺនិងស្លាប់នេះ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថា បើទោះជាកម្ពុជាស្ថិតក្នុងបរិយាកាសដ៏លំបាកដោយសារកូវីដ-១៩ក៏ដោយ ក៏ការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់នៅតែប្រតិបត្តិបាននូវអភិបាលកិច្ចល្អនិងប្រសិទ្ធភាពខ្ពស់ សម្រាប់ការចូលរួមចំណែកឈានទៅសម្រេចគោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ ដោយធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយ សុខភាពល្អនិងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ។

សម្ដេច ហ៊ុន សែន បានមានប្រសាសន៍ទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ថា៖ «ទោះបីការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់ កំពុងទទួលបាននូវសមិទ្ធផលយ៉ាងមានប្រសិទ្ធភាពខ្ពស់យ៉ាងណាក៏ដោយ ក៏យើងត្រូវតែខិតខំបង្កើនល្បឿនទៀតនៃការលុបបំបាត់ជំងឺគ្រុនចាញ់ទៅតាមផែនការក្នុងឆ្នាំ២០២៥ខាងមុខ»។

សម្ដេចនាយករដ្ឋមន្ត្រីបង្ហាញការសង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល វិស័យឯកជន អង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍ សប្បុរសជន ព្រះសង្ឃ ប្រជាពលរដ្ឋទាំងអស់នឹងបន្តរួមចំណែកចូលរួមសហការគ្នាជាប្រព័ន្ធតួអង្គតែមួយគាំទ្រដល់ការសម្រេចនូវបេសកកម្មលុបបំបាត់ជំងឺគ្រុនចាញ់ឱ្យមានប្រសិទ្ធភាព។

តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា លោកស្រីវេជ្ជបណ្ឌិត លី អាយឡែន (Li Ailan) បានប្រាប់ឱ្យដឹងដែរថា ចាប់តាំងពីឆ្នាំ ២០១៨ មកកម្ពុជាបានបង្ហាញទៅកាន់ពិភពលោកថា ការប្ដេជ្ញាចិត្តមួយប្រកបដោយនិរន្តរភាពក្នុងការឈានដល់គោលដៅដែលមិនបានទៅដល់ពីមុនមកនោះ អាចបកស្រាយពីផលប៉ះពាល់នៃពិភពលោកជាក់ស្តែង។

លោកស្រីបញ្ជាក់ថា៖ «ការប្រែក្លាយនៅក្នុងប្រទេសកម្ពុជាមួយនេះពិតជាអស្ចារ្យខ្លាំងណាស់។ ប្រទេសនេះបានឈានទៅរកការលុបបំបាត់ជំងឺគ្រុនចាញ់ទាំងស្រុង។ ជាមួយគ្នានេះ នៅពេលដែលប្រទេសកម្ពុជាទន្ទឹងរង់ចាំ យើងត្រូវតែចាប់ផ្ដើមនិយាយអំពីអ្វីដែលចាំបាច់ ដើម្បីរៀបចំសម្រាប់ការដាក់ពាក្យសុំវិញ្ញាបនប័ត្រគ្មានជំងឺគ្រុនចាញ់នេះ»។

លោកស្រី លី អាយឡែន បានបន្ថែមថា ប្រទេសកម្ពុជាការសម្រេចលទ្ធផលពិសេសមួយក្នុងរយៈពេល៣ឆ្នាំចុងក្រោយ គឺ១៨០អង្សាដែលបន្ថយជំងឺគ្រុនចាញ់ពី៦៦,០០០នាក់ នៅឆ្នាំ២០១៨ មកនៅ៤,៣២៩នាក់ នាឆ្នាំ២០២១ ។

អង្គការសុខភាពពិភពលោកបានពន្លឿនយ៉ាងខ្លាំងក្លាក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់ ដែលលទ្ធផលទាំងនេះគឺដោយសារប្រទេសកម្ពុជាបានអនុវត្តនូវយុទ្ធសាស្ត្រថ្មី ដូចជា កម្មវិធីជំហានចុងក្រោយចុងក្រោយ (Last mile) ដោយមានអ្នកស្ម័គ្រចិត្តភូមិព្យាបាលជំងឺគ្រុនចាញ់ជាអ្នកអនុវត្តការងារជួរមុខដ៏មានប្រសិទ្ធភាពក្នុងភូមិដែលមានការចម្លងនៅខ្ពស់ និងនៅក្នុងភូមិ។

តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជារូបនេះបានសង្កត់ធ្ងន់ថា ដើម្បីឈានទៅទទួលបាននូវវិញ្ញាបណ្ណបត្រគ្មានជំងឺគ្រុនចាញ់សម្រាប់ប្រទេស គួរតែចាប់ផ្ដើមកត់ត្រានូវសកម្មភាពការងារវាយតម្លៃនូវខេត្ត-ស្រុកដែលគ្មានជំងឺគ្រុនចាញ់កន្លងមក ខេត្ត-ស្រុកដែលសម្រេចបានសូន្យករណីជំងឺគ្រុនចាញ់ ត្រូវរកវិធីបង្ការការវិលត្រឡប់នៃជំងឺគ្រុនចាញ់ និងចុងក្រោយសូមបង្កើត និងពង្រីកការតាមដានប្រសិទ្ធភាពថ្នាំនៃជំងឺគ្រុនចាញ់។

> យើងត្រូវយកចិត្តទុកដាក់ខ្ពស់ទាំងអស់គ្នាលើបញ្ហាជំងឺគ្រុនចាញ់ ដើម្បីលើកកម្ពស់សុខភាព គុណភាពនៃការរស់នៅ និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋយើង សមស្របនឹងដំណើរវិវត្តនៃសភាពការណ៍សង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ដែលកំពុងអភិវឌ្ឍន៍តាមព្រំដែន និងអេកូទេសចរណ៍ធម្មជាតិព្រៃភ្នំ



## វដ្តនៃការចម្លងជំងឺគ្រុនចាញ់





ជំងឺគ្រុនចាញ់បង្ករឡើងដោយមូសដែកគោលញី



អភិបាលខេត្តកំពង់ស្ពឺ លោក វ៉ី សំណាង បានឱ្យដឹងដែរថា ស្ថានភាពគ្រុនចាញ់នៅទូទាំងខេត្តកំពង់ស្ពឺ នាប៉ុន្មានឆ្នាំចុងក្រោយនេះបានថយចុះគួរឱ្យកត់សម្គាល់ក្នុងរង្វង់ ៥៥% រៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០១៩មក ដែលក្នុងនោះកាលពីឆ្នាំ២០១៩ មាន ៥៥៣៤ករណី, ឆ្នាំ២០២០ មាន ២៤៦៩ករណី និងឆ្នាំ២០២១ មាន១២២១ករណី)។

លោកបានបន្ថែមថា ដោយឡែកករណីគ្រុនចាញ់សន្ធំ និងចំរុះបានថយចុះក្នុងរង្វង់ ៧០% រៀងរាល់ឆ្នាំផងដែរ ក្នុងនោះ(ឆ្នាំ២០១៩ មាន១៥០៧ករណី ឆ្នាំ២០២០ មាន ៤៧៤ករណី និងឆ្នាំ២០២១ មាន ១២៤ករណី)។

លោក វ៉ី សំណាង បានបញ្ជាក់ទៀតថា ៖ «សម្រាប់ត្រីមាសទី១ ឆ្នាំ២០២២នេះ និន្នាការគ្រុនចាញ់មានការថយចុះផងដែរគឺមានចំនួន ១៩៩ករណីក្នុងនោះ (ប្រភេទគ្រុនចាញ់សន្ធំ និងចំរុះមានចំនួន២៧ករណី និងប្រភេទលាប់ចំនួន ១៧២ករណី) បើប្រៀបធៀបត្រីមាសទី១ រយៈពេលបីឆ្នាំដូចគ្នា (ពី២០២០ ដល់ឆ្នាំ២០២២)»។

លោកថា ចំណែកករណីវិជ្ជមានគ្រប់ទម្រង់ថយចុះក្នុងរង្វង់ ៤៥% ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២១ និងថយចុះ៤៦% ពីឆ្នាំ២០២១ ដល់ត្រីមាសទី១ ឆ្នាំ២០២២នេះ។

ចំណែកលោក គួង ឡូ ប្រធានមន្ទីរសុខាភិបាលខេត្តព្រះវិហារ បានលើកឡើងផងដែរថា អត្រាជំងឺគ្រុនចាញ់ទូទាំងប្រទេសមានការថយចុះ ដោយឡែកសម្រាប់ខេត្តព្រះវិហារ អត្រាថយចុះជំងឺគ្រុនចាញ់ ក៏មានការគួរឱ្យកត់សម្គាល់ផងដែរ ទោះបីស្ថានភាពជំងឺកូវីដ-១៩ មានការឆ្លងរាលដាលខ្លាំងយ៉ាងណាក៏ដោយ។

លោកបានឱ្យដឹងថា អត្រាឆ្លងជំងឺគ្រុនចាញ់ខេត្តព្រះវិហារមានការថយចុះរហូត៥៣.៦% បើប្រៀបធៀបឆ្នាំ២០២០ ។

លោកបានបញ្ជាក់ថា ៖ «អត្រាឆ្លងជំងឺគ្រុនចាញ់ក្នុងខេត្តព្រះវិហារ ទោះបីជាស្ថិតក្នុងស្ថានភាពរីករាលដាលជំងឺកូវីដ១៩ ក៏ដោយ ក៏យើងអាចគ្រប់គ្រងបានឃើញថាមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។ បើពិនិត្យទៅលើគោលដៅ និងផែនការយុទ្ធសាស្ត្រជាតិ គឺយើងបានទៅដល់គោលដៅ ហើយលោកសង្ឃឹមថានឹងទៅដល់គោលដៅលុបបំបាត់ជំងឺគ្រុនចាញ់ទាំងអស់ ក្នុងឆ្នាំ២០២៥ផងដែរ»។

លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រី ក្រសួងសុខាភិបាល បានលើកឡើងថា ជំងឺគ្រុនចាញ់មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សុខភាព ចំណាយលុយកាក់ ការខាតបង់ការងារ ការបាត់បង់ផលិតភាព និងអាយុជីវិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ការអភិវឌ្ឍន សង្គម-សេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរទៀតផង។

លោកមានប្រសាសន៍ថា ៖ «យើងត្រូវយកចិត្តទុកដាក់ខ្ពស់ទាំងអស់គ្នាលើបញ្ហាជំងឺគ្រុនចាញ់ ដើម្បីលើកកម្ពស់សុខភាព គុណភាពនៃការរស់នៅ និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋយើង សមស្របនឹងដំណើរវិវត្តនៃសភាពការណ៍សង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ដែលកំពុងអភិវឌ្ឍន៍តាមព្រំដែន និងអេកូទេសចរណ៍ ធម្មជាតិព្រៃភ្នំ»៕

## ចំនុចគួរកត់សំគាល់៖

### រោគសញ្ញានៃជំងឺគ្រុនចាញ់

1/ រោគសញ្ញានៃជំងឺគ្រុចាញ់កំរិតស្រាល (ctn):

- រីកអណ្ដើក និងរីកថ្លើម
- ស្លេកស្លាំង
- មានខាន់លឿតលើស្បែក
- ឈឺក្បាល




### រោគសញ្ញានៃជំងឺគ្រុនចាញ់

1/ រោគសញ្ញានៃជំងឺគ្រុចាញ់កំរិតស្រាល:

- មានវត្តមានប៉ារាសីតនៃមេរោគគ្រុនចាញ់
- គ្រុនក្ដៅ
- រងារញាក់
- ឈឺតាមសន្លាក់ឬឈឺពេញខ្លួនប្រាណ




### រោគសញ្ញានៃជំងឺគ្រុនចាញ់

2/ រោគសញ្ញានៃជំងឺគ្រុចាញ់កំរិតធ្ងន់ (ctn):

- ហើមសួតស្រួចស្រាល ឬអាសន្នផ្លូវដង្ហើម
- អត្រាស្ករក្នុងឈាមចុះតិចជាង 0,40/ក្រាម/ដេសីលីត្រ
- ហូរឈាមដោយឯងៗ
- ទឹកនោមមានពណ៌ក្រហមដោយមានហេម៉ូក្លូប៊ីនច្រើន

### រោគសញ្ញានៃជំងឺគ្រុនចាញ់

2/ រោគសញ្ញានៃជំងឺគ្រុចាញ់កំរិតធ្ងន់:

ថែមលើរោគសញ្ញាខាងលើ នឹងមានសញ្ញាមួយដូចខាងក្រោម:

- កូម៉ាកំរិតទី2
- ប្រកាច់ផ្ទួនៗ (>2ដង/ថ្ងៃ)
- ខ្វះឈាមក្រហមខ្លាំង (ហេម៉ាតូគ្រីត Ht < 20% )

# នាយករដ្ឋមន្ត្រីកម្ពុជា៖ សិស្សនិងនិស្សិតនឹងក្លាយជាក្រុមអាទិភាពនៃយុទ្ធនាការចាក់វ៉ាក់សាំង ថ្នាក់ជាតិ




*អត្ថបទ៖ អរិយបុត្រ*

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នៅព្រឹកថ្ងៃទី ០៣ ខែ ឧសភា បានប្រកាសជាផ្លូវការថា សិស្សានុសិស្សទាំងអស់គឺជាក្រុមអាទិភាពមួយក្នុងចំណោមក្រុមអាទិភាព នៃយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ថ្នាក់ជាតិ ដើម្បីធានាថា ពួកគេទាំងអស់មានសុវត្ថិភាពគ្រប់គ្រាន់សម្រាប់ការបើកសាលាឡើងវិញ។

ថ្លែងក្នុងពិធីជួបសំណេះសំណាលជាមួយសិស្សានុសិស្សចំនួន ១.៧៥៣នាក់ ដែលប្រឡងជាប់និទ្ទេស A ក្នុងឆ្នាំសិក្សា ២០២០-២០២១ ដែលធ្វើឡើងនៅមជ្ឈមណ្ឌលពិព័រណ៍ជ្រោយចង្វារ រាជធានីភ្នំពេញ នាព្រឹកមិញនេះ សម្តេច បានមានប្រសាសន៍ថា មានសិស្សសរុបប្រមាណ ៣លាននាក់ ហើយ ពួកគេទាំងអស់ត្រូវតែមានភាពស៊ាំប្រឆាំងនឹងជំងឺរាតត្បាត កូវីដ-១៩ ។

សម្តេច បានបន្ថែមថា វ៉ាក់សាំង Pfizer COVID-19 ដែលទើបមកដល់ថ្មីចំនួន ២ លានដូស ដែលផ្តល់ដោយសហរដ្ឋអាមេរិក ដល់ប្រទេសកម្ពុជា តាមរយៈយន្តការ COVAX នឹងត្រូវប្រើប្រាស់ជាដូសជំរុញដល់សិស្សានុសិស្ស។

សម្តេច បានថ្លែងថា ប្រជាពលរដ្ឋជិត ១៥លាននាក់ ក្នុងចំណោមប្រជាពលរដ្ឋសរុប ១៦លាននាក់ បានទទួលវ៉ាក់សាំងតាមកម្រិតមូលដ្ឋាន បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំង ធ្វើឡើងដោយគ្មានការរើសអើង។

សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ សិស្សានុសិស្សចំនួន ៧២.០១៦ នាក់ ឬ ៦៥.៦៥ភាគរយនៃសិស្សសរុប ១១៤.១៨៧ នាក់ដែលអង្គុយប្រឡងមធ្យមសិក្សាទុតិយភូមិបានទទួលសញ្ញាបត្រ។ ក្នុងចំណោមសិស្សដែលទទួលបាននិទ្ទេស A មានចំនួន ១.៧៥៣ នាក់, ៥.២១៥ទទួលបាននិទ្ទេសB ; ១១.៦៣៤ បាននិទ្ទេស C; ២៣.៤៩៩ បាននិទ្ទេស D; និង ២៩.៩១៥ បាននិទ្ទេស E៕

# លោក អូន ព័ន្ធមុនីរ័ត្ន ៖ «វិស័យអប់រំនៅកម្ពុជា កំពុងបោះជំហានទៅរកទម្រង់នៃការអប់រំតាមបែបឌីជីថល»

*អត្ថបទ៖ អមរិន្ទ ដានុត*



មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងថា ស័យអប់រំ កំពុងបោះជំហានទៅរកទម្រង់នៃការអប់រំតាមបែបឌីជីថល ដែលទម្រង់នៃការអប់រំបែបនេះ កំពុងឆ្លើយតបយ៉ាងប្រត្យក្សទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥ ។

នេះជាការថ្លែងឡើងដោយ លោក អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២០-២០២១ និងលើកទិសដៅឆ្នាំសិក្សា២០២១-២០២២ កាលពីថ្ងៃទី២៥ ខែមេសា កន្លងទៅនេះ។

លោកបានមានប្រសាសន៍ថា៖«ខ្ញុំពិតជារីករាយ និងមានមោទនភាពខ្ពស់ ដោយបានកត់សម្គាល់ឃើញថា វិស័យអប់រំ កំពុងបោះជំហានទៅរកទម្រង់នៃការអប់រំតាមបែបឌីជីថល ដែលទម្រង់នៃការអប់រំបែបនេះ កំពុងឆ្លើយតបយ៉ាងប្រត្យក្សទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥»។

លោក អូន ព័ន្ធមុនីរ័ត្ន ក៏បានកោតសរសើរចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា អង្គភាពក្រោមឱវាទ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត គ្រឹះស្ថានសិក្សាគ្រប់កម្រិត លោកគ្រូ អ្នកគ្រូ ដែលបានខិតខំបំពេញកាតព្វកិច្ច ក្នុងការអភិវឌ្ឍវិស័យអប់រំ ដល់សិស្សានុសិស្ស ក្នុងអំឡុងនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ។

សន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ ត្រូវបានប្រារព្ធឡើងក្នុងគោលបំណងពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ការអនុវត្តការងារប្រចាំឆ្នាំធៀបនឹងទិសដៅដែលបានដាក់ចេញក្នុងសន្និបាតកន្លងមក ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ។

លោកបានបន្ថែមថា សន្និបាតអប់រំ បានផ្តល់កាលានុវត្តភាពសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា បុគ្គលិកអប់រំថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ក្រសួងពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ពិភាក្សាអំពីការបំពេញការងារ កំណត់ពីបញ្ហាប្រឈមជាក់លាក់សម្រាប់ឆ្នាំខាងមុខ និងឯកភាពលើសកម្មភាពចាំបាច់មួយចំនួន។

លោក អូន ព័ន្ធមុនីរ័ត្នថា៖«លទ្ធផលសន្និបាតអប់រំ នឹងផ្តល់ជាធាតុចូលដ៏មានសារសំខាន់សម្រាប់កែលម្អផែនការយុទ្ធសាស្ត្រវិស័យអប់រំ រៀបចំផែនការយុទ្ធសាស្ត្រថវិកា ផែនការវិនិយោគសាធារណៈ ផែនការប្រតិបត្តិប្រចាំឆ្នាំ»។

ឆ្លៀតក្នុងឱកាសនេះ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោក ហង់ជួន ណារ៉ុន ក៏បានលើកឡើងផងដែរថា ក្នុងឆ្នាំ២០២២នេះ សន្និបាតអប់រំបានសម្រេចដាក់ចេញវិធានការកែទម្រង់វិស័យអប់រំដំណាក់កាលទី៣ គឺ ការកសាងប្រព័ន្ធនិងការអភិវឌ្ឍសមត្ថភាព ដោយដាក់ឱ្យអនុវត្តអភិក្រមស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផល ឆ្ពោះទៅរកការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធ និងតាមបែបអនុវិស័យ ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ។

លោក ហង់ជួន ណារ៉ុន បានឱ្យដឹងថា គិតត្រឹមឆ្នាំសិក្សា ២០២១-២០២២ សាលាមត្តេយ្យសិក្សា និងគ្រឹះស្ថានសិក្សាចំណេះទូទៅទាំងសាធារណៈនិងឯកជនមានចំនួន ១៨ ៤៣០ ក្នុងនោះមត្តេយ្យសិក្សាសហគមន៍ ៣ ០៨៣កន្លែង គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ ១៣ ៦៨១ និងគ្រឹះស្ថានសិក្សាឯកជន ១ ៦៦៦ ។

សិស្សសរុបមានចំនួន ៣ ៥៨៩ ០២៥ នាក់ ក្នុងនោះសិស្សមត្តេយ្យសិក្សាសហគមន៍ ៧១ ៣៩៩ នាក់ សិស្សគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ ៣ ២៧៧ ០៧៦ នាក់ និងសិស្សគ្រឹះស្ថានសិក្សាឯកជន ២៤០ ៥៥០ នាក់។

ជាមួយគ្នានោះដែរ លោករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចនាយករដ្ឋមន្ត្រី ដែលបានផ្តល់អាទិភាពឱ្យមានយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដល់បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ដើម្បីឆ្លើយតបទៅនឹងការសិក្សាក្នុងគន្លងប្រក្រតីភាពថ្មី និងការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ៕

# គិតត្រឹមឆ្នាំ២០២០ កម្ពុជាបានកត់ត្រាមូស មានជិត៣០០ប្រភេទ

*អត្ថបទ៖ ផល សុផានិត*

ប្រទេសកម្ពុជា ត្រឹមឆ្នាំ២០២០ មានការកត់ត្រាមូសបានចំនួន២៩០ប្រភេទ ស្មើនឹង២០ពួក ដោយក្នុងនោះ ៤៩ប្រភេទជាកំណត់ត្រាថ្មី ហើយមូស ៤៣ប្រភេទមានជាប់ពាក់ព័ន្ធនឹងការបង្កជំងឺ (Maquart et al., 2020)។ តាមការវាយតម្លៃជំងឺបង្កឡើងដោយសត្វល្អិតមានច្រើនជាង១៧% នៃជំងឺឆ្លងសរុប និងបណ្តាលឱ្យ មនុស្សស្លាប់ជាងមួយលាននាក់ក្នុងមួយឆ្នាំៗ ហើយបានសាយភាយទៅគ្រប់ទីកន្លែងពាសពេញពិភពលោកតាមរយៈទង្វើរបស់មនុស្សដូចជាការដឹកជញ្ជូនសកម្មភាពទេសចរណ៍ ។ល។

បើតាមក្រសួងបរិស្ថានអោយដឹងថា មូសជាសត្វល្អិតមានស្លាប មានមាត់ជាទ្រនិចស្រួចសម្រាប់ខាំជញ្ជក់ (វចនានុក្រមខ្មែរ ១៩៦៧)។ ជាទូទៅ មូសញីរស់នៅដោយបឺត ជញ្ជក់ឈាមមនុស្ស និងសត្វដើម្បីចិញ្ចឹមជីវិត និងបង្កកំណើត ចំណែកមូសឈ្មោលបឺតជញ្ជក់ទឹកដមផ្កាជាអាហារ។ មូសត្រូវបានចាត់ចូលក្នុងអំបូរគូលីស៊ីដេ (Culicidae) ហើយបច្ចុប្បន្នត្រូវបានកត់ត្រាថាមានសរុបប្រមាណជាជាង ៣៦០០ប្រភេទ នៅលើ សកលលោក។

ក្នុងចំណោមប្រភេទសត្វល្អិតបង្កជំងឺ សត្វមូសចំនួនបីពួកត្រូវបានកំណត់ជាភ្នាក់ងារចម្លងជំងឺសកម្មជាង គេដូចជា មូសក្នុងពួកអេដេស (Aedes) ជាភ្នាក់ងារបង្កើរជំងឺគ្រុនឈាម (Dengue) គ្រុនឈឹក (Chikungunya) ហ្ស៊ីកា (Zika) ពួកអាណូផេលេស (Anopheles) ជាភ្នាក់ងារបង្ករជំងឺគ្រុនចាញ់ (Malaria) និងពួកគូលិច Culex ជាភ្នាក់ងារបង្ករជំងឺគ្រុនលឿង (Yellow fever) និងជំងឺរលាកខួរក្បាលជប៉ុន(Japanese Encephalitis) ហើយមូសទាំងបីពួកនេះសុទ្ធតែជាភ្នាក់ងារបង្ករជំងឺជើងដំរី (Elephantiasis)។

ជាក់ស្តែងនៅប្រទេសកម្ពុជាជំងឺគ្រុនឈាមដែលមានមូសខ្លា (Aedes aegypti) ជាភ្នាក់ងារចម្លង ត្រូវបានចាត់ទុកថាជាជំងឺគួរឱ្យកត់សម្គាល់បំផុតបន្ទាប់ពីមានការផ្ទុះឡើងនៅឆ្នាំ១៩៩៥ ដោយធ្វើឱ្យមានអ្នកជំងឺស្លាប់ជាង៤០០នាក់។ ចំណែកជំងឺគ្រុនចាញ់ដែលមានភ្នាក់ងារចម្លងជាមូសដែកគោល (ចំនួន៤ប្រភេទគឺ៖ Anopheles minimus, A. dirus, A. maculatus, A. aconitus) មានអត្រាចម្លងថយចុះក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយ ប៉ុន្តែវាបានកើនឡើងវិញម្តងទៀតនៅឆ្នាំ២០១៧ ។

នៅទីក្រុងភ្នំពេញ ការសិក្សាអំពី សត្វមូសរយៈពេលពេញមួយឆ្នាំក្នុងឆ្នាំ២០២០ ដោយនិស្សិតផ្នែក អភិរក្សជីវៈចម្រុះនៃសាកវិទ្យាល័យភូមិន្ទភ្នំពេញ សហការជាមួយវិទ្យាស្ថានប៉ាស្ទ័របានរកឃើញមូសចំនួន១០ប្រភេទ ក្នុងនោះមូសក្នុងពួកអេដេស ចាប់បានសំណាកច្រើនជាងគេពោលគឺប្រមាណ ៨៧% នៃចំនួនសំណាកមូស សរុបហើយប្រភេទមូសចាប់បានសំណាកតិចបំផុតគឺ Toxorhynchites splendens (Khin in prep)។

សូបញ្ជាក់ផងដែរថាប្រភេទមូសToxorhynchites splendens ត្រូវបានចាត់ទុកថាជាប្រភេទសូចនាករក្នុងការគ្រប់គ្រងប្រភេទមូសផ្សេងៗ ព្រោះថាដង្កូវទឹករបស់មូស ប្រភេទ នេះស៊ីដង្កូវទឹករបស់ប្រភេទមូសផ្សេងៗទៀត ហើយមូសប្រភេទនេះក៏មិនមានបង្កជំងឺដែរ (Nyamah, 2011)៕



# រូបចម្លាក់ព្រះក្រឹស្ណៈគោវិធន ពីភ្នំដា ប្រទេសកម្ពុជា ដាក់តាំងនៅសារមន្ទីរជាតិនៅសហរដ្ឋអាមេរិក

*អត្ថបទ៖ អមរិន្ទ ដានុត*

រូបចម្លាក់ព្រះហិណ្ឌូ ក្រឹស្ណៈគោវិធន ដែលមានអាយុកាល ១៥០០ ឆ្នាំ និងវត្ថុបូរាណដទៃទៀតរបស់កម្ពុជា ត្រូវបានដាក់តាំងនៅសារមន្ទីរជាតិសិល្បៈអាស៊ាន Smithsonian ក្នុងទីក្រុង Washington ពីថ្ងៃទី ៣០ ខែមេសា ដល់ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០២២នេះ ។

សារមន្ទីរជាតិសិល្បៈអាស៊ាន Smithsonian ដាក់បង្ហាញរូបចម្លាក់ព្រះក្រឹស្ណៈគោវិធន ពីភ្នំដា ស្រុកអង្គរបូរីរបស់ប្រទេសកម្ពុជា ដែលជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការជាយូរមក លើការអភិរក្សវប្បធម៌ រវាងសហរដ្ឋអាមេរិកនិងប្រទេសកម្ពុជា។

ស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា បានឱ្យដឹងថា ពិព័រណ៍នេះមានឈ្មោះថា «បង្ហាញព្រះក្រឹស្ណៈគោវិធន៖ ដំណើរទៅកាន់ភ្នំដ៏ពិសិដ្ឋនៅកម្ពុជា» បានដាក់បង្ហាញ រូបចម្លាក់ព្រះសាសនាហិណ្ឌូ ដើម្បីការពារប្រជារាស្ត្រព្រះអង្គពីព្យុះភ្លៀងដែលបង្កើតឲ្យមានឡើងដោយព្រះមួយដែលមានការខឹងសម្បា។ កន្លងមក ពិព័រណ៍នេះត្រូវបានរៀបចំធ្វើនៅសាមន្ទីរសិល្បៈ Cleveland Museum of Arts។

លោក W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា បានលើកទឹកចិត្តឲ្យសាធារណជនទស្សនាពិព័រណ៍ពិសេសនេះ នៅក្នុងវីដេអូមួយ ដែលត្រូវបានបង្ហោះនៅក្នុងហ្វេសប៊ុក របស់ស្ថានទូតអាមេរិកនៅភ្នំពេញ។

លោកបានមានប្រសាសន៍ថា៖ «ខ្ញុំមានមោទនភាពចំពោះការខិតខំ និងកិច្ចសហប្រតិបត្តិការអស់រយៈពេលដ៏យូរមករបស់យើង ក្នុងការអភិរក្សជួសជុល និងបង្ហាញឲ្យឃើញពីបេតិកភណ្ឌដ៏អស្ចារ្យរបស់ប្រទេសកម្ពុជានៅទូទាំងសាកលលោក»។

ចាប់តាំងពីឆ្នាំ ២០០១ មក សហរដ្ឋអាមេរិក បានផ្តល់ថវិកាចំនួនជាង ៥ លានដុល្លារ ដល់ប្រទេសកម្ពុជា សម្រាប់ការងារអភិរក្សវប្បធម៌ តាមរយៈមូលនិធិឯកអគ្គរដ្ឋទូតសម្រាប់ការអភិរក្សវប្បធម៌ និងថវិកាជំនួយឥតសំណងដទៃទៀត៕



# នាយករដ្ឋមន្ត្រីឱ្យរាជធានីភ្នំពេញនិងក្រុងហាណូយស្វែងរកលទ្ធភាពពង្រីកកិច្ចសហប្រតិបត្តិការ

*អត្ថបទ៖ អរិយបុត្រ*

នាយករដ្ឋមន្ត្រីកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានណែនាំឱ្យពិនិត្យលទ្ធភាពពង្រឹងក្នុងការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យនានាឱ្យកាន់តែល្អប្រសើរថែមទៀត រវាងរាជធានីភ្នំពេញ របស់កម្ពុជា និងទីក្រុងហាណូយ នៃវៀតណាម។

សម្តេច ហ៊ុន សែន បានលើកឡើងបែបនេះក្នុងជំនួបជាមួយលោក ឌិញ ទៀន ហ្សុង សមាជិកការិយាល័យនយោបាយបក្សកុម្មុយនិស្តវៀតណាម និងជាលេខាបក្សកុម្មុយនិស្តវៀតណាម ប្រចាំក្រុងហាណូយ នាវិមានសន្តិភាព ក្នុងរាជធានីភ្នំពេញ។ នេះបើតាមការឱ្យដឹងពីលោក អ៊ាង សុផល្លែត ជំនួយការនាយករដ្ឋមន្ត្រីកម្ពុជា។

នៅក្នុងជំនួបនេះ លោក ឌិញ ទៀន ហ្សុង បានគោរពថ្លែងអំណរគុណសម្តេចតេជោ ហ៊ុន សែន ដែលបានចំណាយពេលវេលាអនុញ្ញាតឱ្យរូប លោក បានចូលជួបសម្តែងការគួរសម និងពិភាក្សាការងារមួយចំនួន។ លោក ក៏បាននាំយកនូវការផ្តាំផ្ញើសាកសួរសុខទុក្ខរបស់ថ្នាក់ដឹកនាំវៀតណាម ជូនសម្តេចតេជោតេជោ ហ៊ុន សែន ផងដែរ។

លោក អ៊ាង សុផល្លែត បានប្រាប់ក្រុមអ្នកព័ត៌មានថា ក្នុងជំនួបនេះ លោក ឌិញ ទៀន ហ្សុន បានវាយតម្លៃខ្ពស់ចំពោះការចាត់វិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ របស់កម្ពុជា។ លោកក៏បានគោរពរាយការណ៍ពីស្ថានភាពជំងឺកូវីដ-១៩ នៅទីក្រុងហាណូយ ក៏ដូចជាស្ថានភាពសេដ្ឋកិច្ច និងទិសដៅអភិវឌ្ឍន៍ក្នុងក្រុងហាណូយផងដែរ។

លោក ឌិញ ទៀន ហ្សុន ក៏បានបង្ហាញការប្តេជ្ញាចិត្តពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងរដ្ឋធានីហាណូយ និងរាជធានីភ្នំពេញ ដោយអនុវត្តន៍រាល់សេចក្តីថ្លែងការណ៍ និងកិច្ចព្រមព្រៀងទាំងឡាយដែលរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាមបានដាក់ចេញ។

ជាកិច្ចឆ្លើយតប សម្តេចហ៊ុនសែនបានសម្តែងនូវក្តីរីករាយចំពោះការរីកចម្រើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទាំងឡាយរវាងកម្ពុជា និងវៀតណាម។ សម្តេច ហ៊ុន សែន បានគូសរំលេចថា ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងវៀតណាម បានកើនឡើងលើសផែនការ ៥ពាន់លានដុល្លារ តែទោះយ៉ាងណាសម្តេចបានជំរុញឱ្យយកចិត្តទុកដាក់បន្ថែមទៀតលើកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

សម្តេចក៏បានណែនាំឱ្យបន្តប្រែក្លាយតំបន់ធ្លាប់ជាសមរភូមិប្រយុទ្ធតាមព្រំដែនកាលពីអតីតកាល ឱ្យទៅជាតំបន់អភិវឌ្ឍន៍ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ពាណិជ្ជកម្មជាដើមហើយ ក៏បានណែនាំឱ្យបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យនានា រវាងរាជធានីភ្នំពេញ និងក្រុងហាណូយ៕

# លោកអភិបាល អូលីវីយ៉េ ផ្មិតហាស្មេរ ទទួលបានមេដាយថ្នាក់ «ជាតូបការ»











*អត្ថបទ៖ ដាលីស*

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈលោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានបំពាក់មេដាយថ្នាក់ «ជាតូបការ» ជូនលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញលោក អូលីវីយ៉េផ្មិតហាស្មេរ ដើម្បីតបស្នងទៅនឹងកិច្ចការដែលលោកបានជួយអភិវឌ្ឍស្ទើរគ្រប់វិស័យទាំងអស់នៅក្នុងខេត្តតាកែវ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២ នាវិទ្យាស្ថានសន្តប៉ូល ក្នុងភូមិអង្គគី ស្រុកត្រាំកក់។

ថ្លែងប្រាប់សារព័ត៌មាន លោក អូលីវីយ៉េ បានឱ្យដឹងថា នេះជាមេដាយជាតូបការ ហើយនេះជាអ្វីដែលជាសមិទ្ធិផលក្នុងការប្រមូលនូវគ្រប់ស្នាដៃក្នុងព្រះសហគមន៍ តាំងពីឆ្នាំ ២០១០ រហូតដល់ ២០២២ នៅក្នុងខេត្តតាកែវនេះ។

លោកមានប្រសាសន៍ថា៖«យើងបានជួយអភិវឌ្ឍទៅលើវិស័យជាច្រើន ទាំងវិស័យអប់រំវិស័យសង្គម ការជួយជនពិការ សិប្បកម្ម សិល្បៈ សុខភាព និងវិស័យសាសនា ដែលណែនាំឱ្យមនុស្សនានាដែលអស់សង្ឃឹមឱ្យមានសង្ឃឹមឡើងវិញ។ ដូចនេះអ្វីៗទាំងអស់បានធ្វើឲ្យរាជរដ្ឋាភិបាលទទួលស្គាល់»។

ទាក់ទងនឹងសមិទ្ធិផលដែលលោកទទួលបាននេះដែរ លោកអភិបាលក៏បានបញ្ជាក់ផងដែរថា ទាំងអស់នេះមិនមែនស្នាដៃលោកផ្ទាល់តែឯងនោះទេ ប៉ុន្តែជាស្នាដៃរបស់ព្រះសហគមន៍កាតូលិក ជាពិសេសនៅក្នុងខេត្តតាកែវតែម្តង។

លោកអូលីវីយ៉េ បានថ្លែងថា ៖ «ខ្ញុំសូមអរគុណដល់សហការីរបស់ខ្ញុំទាំងអស់ ដែលបានធ្វើឱ្យគ្រប់សកម្មភាពរបស់យើង ទាំងការអប់រំ ទាំងការអភិវឌ្ឍ និងទាំងសិល្បៈ ដែលទទួលជោគជ័យបាននេះ។ នេះជាការអស្ចារ្យនិងជោគជ័យសម្រាប់យើងទាំងអស់ និងជាកម្លាំងមួយពិសេសថ្មីដើម្បីឱ្យយើងទៅមុខទៀត»។

នាឱកាសនោះដែរ វិទ្យាស្ថានសន្តប៉ូល ក៏បានប្រារព្ធបើកបវេសនកាលឆ្នាំសិក្សាថ្មី «ឆ្នាំបៃតង» ជាផ្លូវការក្រោមអធិបតីភាពលោក សាយ សំអាល់, លោក អ៊ូច ភា អភិបាលខេត្តតាកែវ និងប្រគល់សញ្ញាបត្រជូននិស្សិតសញ្ញាបត្របរិញ្ញាបត្ររង និងបរិញ្ញាបត្រចំនួន១១៤នាក់ផងដែរ។

ស្ថាបនិកវិទ្យាស្ថានសន្តប៉ូល លោកអភិបាល អូលីវីយ៉េ បានលើកឡើងថា នៅក្នុងឆ្នាំសិក្សា ២០២១ ដោយសារការរាលដាលនៃមេរោគកូវីដ១៩ វិទ្យាស្ថានមិនបានបើកបវេសនកាលត្រឹមត្រូវទេ គឺមានតែសាស្ត្រាចារ្យដែលបានបង្រៀនតាមអនឡាញ ដើម្បីឱ្យនិស្សិតបន្តការសិក្សា ដោយទទួលបានលទ្ធផលជោគជ័យ។ លោកមានប្រសាសន៍ថា ៖ «ឆ្នាំនេះខ្ញុំបានប្រកាសឆ្នាំបៃតង ដោយសារយើងមើលកូវីដ១៩ និងពណ៌បៃតងជាពណ៌នៃសេចក្តីសង្ឃឹម។ ដូច្នេះនៅក្នុងឆ្នាំបៃតងនេះ ឱ្យយើងមើលគ្រប់វិស័យ សូមឱ្យការសិក្សាជោគជ័យ មានទំនាក់ទំនងប្រាកដ មិនមែនតាមហ្សូម និងអនឡាញ ប៉ុន្តែឱ្យយើងខិតខំការពារថែរក្សាបរិស្ថាន ដាំបន្លែ យកចិត្តទុកដាក់នឹងសុខភាពក៏ដូចជាទេពកោសល្យដើម្បីឱ្យយើងទៅជាមនុស្សដ៏ពេញលក្ខណៈ។ នៅពេលយើងនិយាយពីពណ៌បៃតង ជាពណ៌ដែលមើលពីអនាគត និងក្តីសង្ឃឹមរបស់យើង»។

លោកអូលីវីយ៉េបានធ្វើការផ្តាំផ្ញើដល់និស្សិតទាំងអស់ផងដែរថា «តស៊ូ និងយកចិត្តទុកដាក់» ទោះបីមានកូវីដឬមិនមានកូវីដ តែតស៊ូដើម្បីរៀនសូត្រ តស៊ូដើម្បីរៀបចំអនាគត និងយកចិត្តទុកដាក់ទាំងការៀនសូត្រ ការធ្វើការងារ និងការរៀបចំអនាគត។

ជាមួយគ្នានេះដែរលោក សាយ សំអាល់ បានធ្វើការសាទរចំពោះលោកអភិបាល អូលីវីយ៉េដែលព្រះមហាក្សត្រសព្វព្រះរាជហឫទ័យប្រទានងារជា «ឯកឧត្តម» ហើយលោកក៏បានសាទរដល់និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ដែលជាការបើកទំព័រថ្មីនៅក្នុងជីវិតផ្ទាល់ខ្លួន។

លោកបានថ្លែងថា ៖ «ថ្ងៃនេះខ្ញុំសូមផ្សារភ្ជាប់ប្រសាសន៍ពររបស់ឯកឧត្តមហ៊ុនម៉ាណែត ដែលជាជនគំរូមួយនៅកម្ពុជា ដោយកោតសរសើរលោកអភិបាលដែលបានរក្សានូវមរតកជំនាន់មុន ចូលរួមពូនជ្រុំកសាងនូវសមិទ្ធផលផ្សេងៗទៀតរួមទាំងបុគ្គលខ្លួនឯង មិនត្រឹមតែព្រះសហគមន៍តែប៉ុណ្ណោះទេ និងចូលរួមកសាងថ្នាលសម្រាប់អ្នកជំនាន់ក្រោយទៀតផងដែរ»។

ប្រទេសរឹងមាំផ្តើមចេញពីយើងមុនគេ និងត្រូវរកឱ្យឃើញនូវទេពកោសល្យផ្ទាល់ខ្លួនឱ្យបាន នោះទើបយើងអាចរីកចម្រើន។ នេះបើតាមការបញ្ជាក់របស់លោក សាយ សំអាល់។

វិទ្យាស្ថានសន្តប៉ូលជាគ្រឹះស្ថានឧត្តមសិក្សាកាតូលិកដំបូងគេបង្អស់តែមួយគត់នៅក្នុងប្រទេសកម្ពុជា។ វិទ្យាស្ថាននេះបង្កើតឡើងជាផ្លូវការនៅក្នុយងឆ្នាំ២០០៩ ក្រោមគំនិតផ្តួចផ្តើមនិងទទួលខុសត្រូវខ្ពស់របស់លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយ៉េ ដែលជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានសន្តប៉ូល។

រយៈពេលជាង១០មកនេះ វិទ្យាស្ថានសន្តប៉ូលបានបណ្តុះបណ្តាលនិស្សិតលើបរិញ្ញាបត្រជំនាញវិស្វកម្ម Software ទូរគមនាគមន៍និងបណ្តាញ ជំនាញអក្សរសាស្ត្រអង់គ្លេស ជំនាញគ្រប់គ្រងទេសចរណ៍ ក្សេត្រសាស្ត្រ ជំនាញសង្គមកិច្ច។

រីឯបរញ្ញាបត្ររង វិទ្យាស្ថានបណ្តុះបណ្តាលលើជំនាញចំនួន៦ រួមមាន៖ អភិវឌ្ឍកម្មវិធីកុំព្យូទ័រ គ្រប់គ្រងប្រព័ន្ធនិងបណ្តាញកុំព្យូទ័រ ផលិតកម្មដំណាំហូបផ្លែនិងបន្លែ វេជ្ជសាស្ត្រសត្វ ភាសាអង់គ្លេស សណ្ឋាគារ និងបដិសណ្ឋារកិច្ច៕

# ព្រះសហគមន៍ប្រារព្ធពិធីបុណ្យហែស្លឹកដើម្បីនឹកដល់ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

*អត្ថបទ៖ ដាលីស*

ក្បួនដង្ហែដែលមានក្រុមមនុស្សកាន់ស្លឹកដែលបានរចនាជារូបផ្សេងៗ អមដោយសំឡេងស្គរ របាំត្រុដិ និងរបាំក្ងោកយ៉ាងឱឡារឹក បានហែចេញពីផ្ទះបងស្រីឧបការគុណ មកកាន់ព្រះវិហារព្រះកុមារយេស៊ូ ក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីនៅភ្នំពេញ នាថ្ងៃទី ១០ ខែមេសា កន្លងទៅនេះ។



ពិធីនេះប្រារព្ធធ្វើឡើងតាមរបៀបព្រះសហគមន៍កាតូលិកនៅកម្ពុជា ក្រោមអធិបតីភាព លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ជ្មឹតហស្លេ តាមទំនៀមទម្លាប់ព្រះសហគមន៍កាតូលិកក្នុងថ្ងៃដំបូងដែលព្រះសហគមន៍ឈានដល់សប្តាហ៍ពិសិដ្ឋ ដោយរំឭកដល់ប្រជាជនអបអរសាទរព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម ដើម្បីចូលក្នុងអាថ៌កំបាំងរបស់ព្រះជាម្ចាស់ដោយព្រះបុត្រាត្រូវរងទុក្ខលំបាក សោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿងតាមជំនឿព្រះសហគមន៍កាតូលិក ។

នៅក្នុងឱកាសនេះដែរ លោកអភិបាលព្រះសហគមន៍មានប្រសាសន៍ណែនាំ ដោយលើកទឹកចិត្តគ្រីស្តបរិស័ទទាំងអស់ ដែលបានធ្វើដំណើររួមគ្នាជាមួយព្រះសហគមន៍ក្នុងរយៈពេល៤០ថ្ងៃនៃរដូវអប់រំពិសេសនេះថា ៤០ថ្ងៃនេះយើងបានចូលក្នុងវាលរហោស្ថាន ដោយខិតខំចូលក្នុងវាលរហោស្ថាននៃជីវិតរបស់យើង ដើម្បីតស៊ូ កែប្រែចិត្តគំនិតដើម្បីភ្ជាប់ជាមួយព្រះហឫទ័យព្រះយេស៊ូថែមទៀត។

ជាងនេះទៅទៀតតាមរយៈថ្ងៃដំបូងនៃសប្តាហ៍ពិសិដ្ឋនេះ លោកអភិបាលមានប្រសាសន៍ថា នេះជាពេលវេលាដែលយើងរួមជាមួយមហាជនពីដើមកោតសរសើរព្រះអម្ចាស់យេស៊ូ ដែលយាងចូលក្នុងទីក្រុងយេរូសាឡឹម ហើយក៏ជាពេលវេលាដែលយើងចូលរួមនៅក្នុងការរងទុក្ខលំបាករបស់ព្រះយេស៊ូ ដើម្បីធ្វើដំណើរយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូដែលជប់លៀងជាមួយក្រុមសាវ័ក សោយព្រះទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។

លោកអភិបាលក៏បានលើកទឹកចិត្តបន្ថែមដល់គ្រីស្តបរិស័ទខ្មែរទាំងអស់ដែលកំពុងតែត្រៀមចូលក្នុងឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងក្រើនរំឭកគ្រីស្តបរិស័ទឱ្យនឹកឃើញដល់សប្តាហ៍ពិសិដ្ឋ នឹកដល់ព្រះយេស៊ូសោយទិវង្គត និងមានព្រះជន្មថ្មីជាសញ្ញាសម្គាល់នៃជីវិតថ្មីដែលកើតឡើងនៅក្នុងដួងចិត្តរបស់យើង នៅលើទឹកដីរបស់យើង។

ប្រធានគណៈកម្មការព្រះសហគមន៍ យុន កញ្ញា និយាយថា «អត្ថន័យនៃបុណ្យហែស្លឹកចំពោះខ្ញុំ គឺអបអរសាទរព្រះយេស៊ូជាស្តេចយាងចូលក្រុងយេរូសាឡឹម ត្រៀមខ្លួនចូលសប្តាហ៍ពិសិដ្ឋរួមទុក្ខលំបាករបស់ព្រះយេស៊ូ ជាពេលវេលាដែលត្រូវជិតស្និទ្ធជាមួយព្រះយេស៊ូ និងត្រៀមខ្លួនទទួលអំណរសប្បាយដែលព្រះយេស៊ូមានព្រះជន្មដ៏រុងរឿងអស់កល្បជានិច្ច ដោយថ្វាយទុក្ខលំបាក កង្វល់ អំណរសប្បាយ និងមានក្តីសង្ឃឹមអាចរួមជាមួយព្រះអង្គនៅស្ថានបរមសុខ គឺទទួលជីវិតអស់កល់ជានិច្ច»

ពិធីនេះត្រូវបានប្រារព្ធឡើង ដោយមានការណែនាំពីលោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ ដាមីញ៉ាំង ហ្វារនី ដោយមានអានអត្ថបទព្រះគម្ពីរដំណឹងល្អ ច្រៀងលើកតម្កើងព្រះជាម្ចាស់ និងប្រោសទឹកព្រះពរលើស្លឹករួមជាមួយគ្រីស្តបរិស័ទ រួចហែទៅកាន់ព្រះវិហារព្រះកុមារយេស៊ូយ៉ាងឱឡារឹក ។

លោកអភិបាលអូលីវីយេ គោះទ្វារព្រះវិហារ៣ដង ដោយប្រកាសឱ្យទ្វារបើកចំហរ ដើម្បីឱ្យព្រះយេស៊ូព្រះមហាក្សត្រនៃពិភពលោកប្រកបដោយសិរីរុងរឿងយាងចូល និងអញ្ជើញគ្រីស្តបរិស័ទចូលទៅក្នុងព្រះវិហារ ដើម្បីប្រារព្ធពិធីបុណ្យអភិបូជាដែលជាការរំឭកពីអាថ៌កំបាំងនៃការសង្គ្រោះតាមជំនឿព្រះសហគមន៍កាតូលិក។

ឆ្លៀតក្នុងឱកាសដែលព្រះសហគមន៍នឹករឭកដល់ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹមដើម្បីរងទុក្ខលំបាក និងសោយទិវង្គតព្រោះតែភាពប្រណែននិងចិត្តលោភលន់របស់មនុស្សលោកនេះដែរ លោកអភិបាលអូលីវីយេ ណែនាំគ្រីស្តបរិស័ទនៅក្នុងធម្មទេសនាថា «ទោះបីលោកពីឡាត់មិនបានរកឃើញទោសព្រះយេស៊ូ តែគេបានពុករលួយដោយលោកយ៉ូដាសបានលក់ព្រះយេស៊ូព្រោះតែប្រាក់»។

លោកអភិបាលបន្តថា ការប្រណែន ការ ស្រេកឃ្លានអំណាច និងពុករលួយ នាំឱ្យមានសង្គ្រាមដូចប្រទេសអ៊ុយក្រែនណឹងរុស្ស៊ីសព្វថ្ងៃ។ លោកអភិបាលបន្ថែមថា ព្រះយេស៊ូជាមាគ៌ានៃសេចក្តីសុខសាន្ត និងសេចក្តីសុខសាន្តតាមរបៀបព្រះយេស៊ូគឺ៖ យើងជាអ្នកតូចជាងគេនិងបម្រើគេ ចេះអាណិតមេត្តា កុំឆ្លើយនឹងហិង្សាដោយអំពើហិង្សា ណែនាំឱ្យកាត់បន្ថយសេចក្តីស្អប់ ទោះពេលវេលាចុងក្រោយលើកលែងទោស និងជឿទុកចិត្តថ្វាយគ្រប់យ៉ាងទៅព្រះបិតាទាំងអំណរសប្បាយនិងទុក្ខព្រួយ៕

# លោកអភិបាលប្រសិទ្ធពរលើប្រេងពិសិដ្ឋសម្រាប់អគ្គសញ្ញានៃការសង្គ្រោះរបស់ព្រះជាម្ចាស់

*អត្ថបទ៖ ដាលីស*

លោកអភិបាល និងលោកបូជាចារ្យជាង៧០អង្គចូលជុំគ្នារព្ធពិធីប្រសិទ្ធពរលើប្រេងពិសិដ្ឋ សម្រាប់ប្រើប្រាស់ក្នុងអគ្គសញ្ញានានារបស់ព្រះសហគមន៍កាតូលិក ដែលធ្វើឡើងនៅព្រះវិហារសន្តសិលា និងសន្តប៉ូល នារាជធានីភ្នំពេញ ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍ទាំងបីភូមិភាគ នាថ្ងៃទី ៦ មេសា ២០២២នេះ។

នៅក្នុងធម្មទេសនានៃពិធីបុណ្យអភិបូជានេះ លោកអភិបាលអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ថា៖ ប្រេងដែលលោកនឹងប្រសិទ្ធពរនៅក្នុងថ្ងៃនេះ គឺសម្រាប់ប្រើក្នុងអគ្គសញ្ញានានា។ លោកបន្ថែមថា «ជាប្រេងនៃអគ្គសញ្ញាដែលផ្តល់ជីវិត ជាប្រេងសម្រាប់អប់រំជំនឿ និងលាបអ្នកជំងឺដើម្បីទទួលកម្លាំងថ្មី»

លោកអភិបាល អូលីវីយេ បន្ថែមថា ប្រេងនៅក្នុងឆ្នាំនេះ នឹងអាចប្រើបន្ថែមទៅលើអគ្គសញ្ញាដែលព្រះសហគមន៍បានខកខានប្រារព្ធកាលពីឆ្នាំកន្លងទៅ ដោយសារជំងឺកូវីដ-១៩ ។

លោកបន្ថែមថា ប្រេងនេះធ្វើឲ្យមនុស្សទៅជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ហើយឆ្នាំនេះព្រះសហគមន៍ក៏សង្ឃឹមថានឹងមានអ្នកទទួលអគ្គសញ្ញាជាបូជាចារ្យម្នាក់ និងមានពិធីតែងតាំងជា ឧបដ្ឋាកផងដែរ។

ប្រេងដែលយើងរៀបចំថ្ងៃនេះ នាំឱ្យយើងអរព្រះគុណព្រះជាម្ចាស់ថែមទៀត សូមឱ្យសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់គង់នៅក្នុងដួងចិត្តរបស់យើង និងណែនាំឱ្យយើងរស់នៅសុខដុមរមនា។

ក្នុងពិធីនោះ តំណាងគ្រីស្តបរិស័ទមកពីព្រះវិហារនានា បាននាំយកប្រេងចំនួន៣ប្រភេទមកដដាក់នៅ មុខអសនៈ ដើម្បីឲ្យលោកអភិបាលទាំងបីភូមិភាគប្រសិទ្ធពរ ក្លាយជាប្រេងសក្ការៈ ទុកប្រើប្រាស់តាមកន្លែងនីមួយៗតាមសេចក្តីត្រូវការ។ ប្រេងពិសិដ្ឋមាន៣យ៉ាងគឺ៖ ប្រេងអ្នកជំងឺ(សម្រាប់លាបផ្តល់កម្លាំងឱ្យអ្នកជំងឺ) ប្រេងអ្នកស្វែងយល់ (សម្រាប់លាបឱ្យអ្នកដែលកំពុងរៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក) និងប្រេងគ្រីស្មា (សម្រាប់លាបឱ្យអ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្ងាស អគ្គសញ្ញាតែងតាំងនានា)។



តាមប្រសាសន៍លោកបូជាចារ្យ ដាមីញ៉ាំង ហ្វារនី ទទួលបន្ទុកនៃគណៈកម្មការរៀបចំពិធីបុណ្យ មានប្រសាសន៍ថា ពិធីនេះព្រះសហគមន៍ហៅថា ពិធីប្រសិទ្ធពរលើប្រេងអភិសេក និងតាមក្បួនពិធីបុណ្យយើងត្រូវប្រារព្ធនៅព្រឹកថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ប៉ុន្តែព្រះសហគមន៍មានសិទ្ធិប្រារព្ធនៅមុនសប្តាហ៍ពិសិដ្ឋដែរ។

លោកបន្ថែមថា ពិធីនេះ បូជាចារ្យភូមិភាគទាំងអស់ត្រូវតែចូលរួមប្រារព្ធជាមួយលោកអភិបាល ដោយសារ ប្រេងពិសិដ្ឋទាំង៣យ៉ាងមានអត្ថន័យថាព្រះជាម្ចាស់សង្គ្រោះពិភពលោក និងយើងប្រើដើម្បីប្រារព្ធអគ្គសញ្ញានានាតាមរបៀបព្រះសហគមន៍កាតូលិក ដែលមានន័យថាព្រះជាម្ចាស់អភិសេកយើងផងដែរ។ លោកដាមីញ៉ាំង បញ្ជាក់ថា យើងប្រារព្ធតែម្តងក្នុងមួយឆ្នាំគឺលោកអភិបាលតែម្នាក់គត់ គឺលោកអូលីវីយេ ដែលបានទទួលអគ្គសញ្ញាតែងតាំងជាអភិបាលដែលអាចប្រសិទ្ធពរលើប្រេងគ្រីស្មា ដើម្បីឱ្យប្រេងគ្រីស្មានេះក្លាយជាប្រេងអភិសេក។

យោងតាមឯកសាររបស់ព្រះសហគមន៍កាតូលិក សហគមន៍គ្រីស្តបរិស័ទបានយកប្រេងទឹកជានិមិត្តរូបនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះអំណោយទានពិសេសរបស់ព្រះជាម្ចាស់ គឺព្រះអង្គជ្រាបចូលក្នុងចិត្តគំនិត ព្រមទាំងប្រទានកម្លាំង និងអំណរសប្បាយដល់អស់អ្នកជឿ៕

# ព្រះវិហារម្ចាស់ក្សត្រីយ៍នៃសន្តិភាពប្រារព្ធខួប១៨ឆ្នាំ នៃការស្រង់ព្រះនាងម៉ារីពីបាតទន្លេមេគង្គ





*អត្ថបទ៖ ដាលីស*

ព្រះសហគមន៍កាតូលិកកម្ពុជា ព្រះវិហារម្ចាស់ក្សត្រីយ៍នៃសន្តិភាព (អរិយក្សត្រ) ក្នុងស្រុកល្វាឯម ខេត្តកណ្ដាលបានប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ដោយអធិដ្ឋានរួមជាមួយព្រះនាងម៉ារីក្នុងឱកាសរំឭកខួប១៨ឆ្នាំនៃការស្រង់រូបសំណាកព្រះនាងម៉ារីទី១ពីបាតទន្លេមេគង្គ។

ពិធីនេះធ្វើឡើង ក្រោមអធិបតីភាពរបស់លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ប៊្រុយណូ កូសម៍ នាព្រឹកថ្ងៃទី២៣ខែមេសាដោយមានគ្រីស្តបរិស័ទចូលរួមជាច្រើននាក់។

នៅក្នុងធម្មទេសនា លោកអភិបាលប៊្រុយណូ កូសម៍ មានប្រសាសន៍ថា ៖ «យើងមកអង្វរព្រះជាម្ចាស់តាមរយៈព្រះនាងម៉ារី។ នៅពេលយើងមកទីនេះ យើងដឹងថាព្រះនាងម៉ារីណែនាំយើងឆ្ពោះទៅកាន់ព្រះជាម្ចាស់ផ្ទាល់»។

លោកអភិបាលបន្តថា អ្វីដែលបានឮ និងអ្វីដែលយើងបានឃើញមិនស្រួល និងពេលខ្លះមិនល្អឱ្យគ្រប់គ្នាឈឺចាប់វេទនា។

លោកអភិបាលភូមិភាគកំពង់ចាម រំលឹកទៀតថា ៖ «សង្គ្រាមមានច្រើននៅក្នុងពិភពលោក នាំឱ្យមានមនុស្សរាប់ពាន់អ្នកស្លាប់ និងរាប់លានអ្នកវេទនា។ សម្ដេចប៉ាបបានណែនាំឱ្យយើងអង្វរសូមសុខសន្តិភាពសម្រាប់ពិភពលោកទាំងមូលតាមរយៈព្រះនាងម៉ារី ជាពិសេសប្រទេសអ៊ុយក្រែន និងរុស្ស៊ី»។

លោកថា ព្រះជាម្ចាស់ចង់ឱ្យយើងអធិដ្ឋានសម្រាប់មនុស្សទាំងអស់ ហើយយើងមិនអាចនៅស្ងៀមបានទេ គឺឱ្យយើងចេះផ្ដល់សាក្ខីភាពពីជំនឿរបស់យើង។

លោកអភិបាលប៊្រុយណូមានប្រសាសន៍ទៀតថា យើងជាគ្រីស្តបរិស័ទ យើងមានតួនាទីក្នុងការនិយាយ ផ្ដល់សក្ខីភាព ដោយសារព្រះយេស៊ូជាកម្លាំងរបស់យើង។ ជីវិតរបស់យើងជាគ្រីស្តបរិស័ទជំនឿរបស់យើងខ្លាំងជាងអាវុធបរិមាណូ។

នៅក្នុងឱកាសនេះដែរ លោក ដាវីឌ ហ្សូរណូ បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍នេះមានប្រសាសន៍ថា ៖ «ព្រះនាងម៉ារីជាម្ដាយយើងខ្ញុំ និងណែនាំឱ្យយើងទៅជាមនុស្សដ៏វិសុទ្ធ»។

លោកបូជាចារ្យ ដាវីដ បញ្ជាក់ថា នៅថ្ងៃនេះយើងសប្បាយរីករាយ ដោយសារជិត២ឆ្នាំមកហើយដែលយើងមិនមានបុណ្យធំដូចនេះ ដោយសារកូវីដ-១៩។ ទើបតែថ្ងៃនេះយើងអាចធ្វើបុណ្យធំដូចមុន និងយើងសប្បាយព្រោះមនុស្សដែលមកអធិដ្ឋានជាមួយព្រះនាងម៉ារីនៅទីនេះ ដែលជាកន្លែងយើងជឿថាព្រះនាងម៉ារីបានជ្រើសរើស ដើម្បីឱ្យបងប្អូនគ្រីស្តបរិស័ទមានជីវិតជិតស្និទ្ធជាមួយព្រះយេស៊ូតាមរយៈព្រះនាងម៉ារី និងជាបេសកកម្មរបស់ព្រះនាងម៉ារីដែលនាំយើងអធិដ្ឋានទៅព្រះជាម្ចាស់ជាមួយព្រះនាងម៉ារីជាម្ដាយរបស់យើង។

លោកបូជាចារ្យរូបនេះ បន្ថែមថា ៖ «ខ្ញុំសង្ឃឹមថាកន្លែងនេះ ជាកន្លែងដែលជួយគ្រីស្តបរិស័ទឱ្យមានជីវិតជាគ្រីស្តបរិស័ទល្អ និងជាកន្លែងដែលគេមកបាន ដើម្បីគិតអំពីជីវិតរបស់គេដោយទទួលក្ដីសង្ឃឹមនៅទីនេះជាមួយព្រះនាងម៉ារី»។

លោកដាវីដ បន្តថា កន្លែងនេះជួយដល់គ្រីស្តបរិស័ទរំឭកពីភាពជាបងប្អូនគ្នា ដោយយើងមានព្រះបិតាតែមួយ និងមានព្រះនាងម៉ារីជាម្ដាយរបស់យើង យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ ជាកន្លែងអធិដ្ឋានពីសន្តិភាព។

ទោះបីជានៅស្រុកខ្មែរមិនមានសង្គ្រាម តែមិនត្រឹមតែជាសន្តិភាពនៅក្នុងសង្គមខ្មែរ ក្នុងគ្រួសារខ្មែរប៉ុណ្ណោះទេ គឺសន្តិភាពសម្រាប់ពិភពលោកដោយយើងមានបេសកកម្មបើកចិត្តគំនិតរបស់យើង មិនមែនគិតអំពីជីវិតផ្ទាល់ខ្លួនតែប៉ុនហ្នឹងទេ។

ព្រះវិហារមាតានៃសន្តិភាពអរិយក្សត្រ មានទីតាំងនៅត្រើយម្ខាងនៃទន្លេមេគង្គ ស្ថិតនៅក្នុងស្រុកល្វាឯម ខេត្តកណ្ដាល។

យុវតី ញ៉ សុគន្ធា មកពីព្រះសហគមន៍ស្អាង ខេត្តកណ្ដាលដែលមកចូលរួមអធិដ្ឋានព្រះនាងម៉ារីនៅអរិយក្សត្រនេះ ឲ្យដឹងថា «ខ្ញុំតែងតែអធិដ្ឋានជាមួយព្រះនាងទាំងនៅទីនេះ និងនៅផ្ទះ»

កញ្ញាគន្ធាបន្ថែមថា៖«ចំពោះខ្ញុំផ្ទាល់ ខ្ញុំជឿលើព្រះនាងម៉ារីច្បាស់ ព្រោះតាំងពីខ្ញុំមកអធិដ្ឋានរាល់មួយឆ្នាំពីរដងគឺគាត់បានផ្ដល់ក្ដីសង្ឃឹមឱ្យខ្ញុំ និងគ្រប់ការងារដែលខ្ញុំធ្វើបានជោគជ័យនៅពេលដែលខ្ញុំបានអធិដ្ឋានជាមួយព្រះនាង ទាំងរឿងបញ្ហាក្នុងគ្រួសារ និងសុខភាពគ្រួសារតែងតែទទួលបានជោគជ័យមកវិញ ហើយក៏ទទួលបាននូវអ្វីដែលយើងចង់បាន»។

រូបសំណាកព្រះនាងម៉ារីទី១ ត្រូវបានស្រង់ចេញពីបាតទន្លេមេគង្គកាលពីថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០០៨ ដោយក្រុមគ្រួសារអ្នកនេសាទដែលជាពុទ្ធបរិស័ទ។ ប៉ុន្មានឆ្នាំក្រោយមក ក្រុមគ្រួសារនេះបានកែប្រែចិត្តគំនិតទទួលដំណឹងល្អ និងបានក្លាយជាគ្រីស្តបរិស័ទកាតូលិក៕

## ជំនឿរបស់ឪពុកម្ដាយធ្វើអោយទារកអាយុ៧ខែម្នាក់ទទួលពិធីជ្រមុជទឹក

*អត្ថបទ៖ ចាន់ ម៉ានុត*

នារាត្រីបុណ្យចម្លងកាលពីពេលថ្មីៗនេះ នៅព្រះវិហារសន្តយ៉ូសែបជុំគិរី នៃមណ្ឌលសកម្មភាពកំពតបានរៀបចំ ពិធីជ្រមុជទឹកដល់ទារកដែលមានអាយុទើបតែ៧ខែក្រោមអធិបតីភាព លោកបូជាចារ្យ ចំនួន៣អង្គ និងមាន គ្រីស្តបរិស័ទចូលរួមយ៉ាងច្រើនកុះករ ។

ក្នុងរាត្រីបុណ្យចម្លងយ៉ាងឱឡារិកនោះ លោកបូជាចារ្យ ឆាល ខាលេស ក្រុមសាសនទូតពីមេ ដែលជាបូជាចារ្យ សម្របសម្រួលនៅក្នុងមណ្ឌលសកម្មភាពកំពត បានមានប្រសាសន៍ថា ៖ អំពីពិធីជ្រមុជទឹកអោយ ទារកម្នាក់នៅជុំគិរីនោះ គឺលោកពុកមានអំណរសប្បាយណាស់ ដោយទារកនោះបានទទួលជីវិតថ្មីដោយរួម ជាមួយព្រះយេស៊ូគ្រីស្ត។

លោកបូជាចារ្យមានប្រសាសន៍ថា៖«កូនក្មេងទាំងអស់ដែលកើតមកសុទ្ធតែមានបាបកម្មរបស់លោកតាអាដាំ និង លោកយាយអេវ៉ា ហេតុនេះហើយពិធីជ្រមុជទឹកគឺព្រះជាម្ចាស់លើកលែងទោសរំដោះបាបនោះដើម្បី អោយកូនក្មេងនោះក្លាយជា ក្មេងបរិសុទ្ធ»។

លោកបូជាចារ្យបន្ថែមថា ការសម្រេចចិត្តរបស់ឪពុកម្ដាយរបស់ទារក ជាអ្វីដែលសំខាន់ព្រោះទារកនឹងទទួលជំនឿបន្តពីឪពុកម្ដាយក្លាយជាគ្រីស្តបរិស័ទ ទទួលការអប់រំជំនឿ និងចូលរួមពិធីបុណ្យទាំងអស់របស់ព្រះសហគមន៍ ហើយត្រូវការការណែនាំពីឪពុកម្ដាយបង្កើត ឪពុកម្ដាយធម៌ និងបងប្អូនគ្រីស្តបរិស័ទ ដើម្បីក្លាយជាបុត្រធីតារបស់ព្រះជាម្ចាស់ ។

នៅក្នុងកម្មវិធីដែលពោរពេញដោយស្នាមញញឹម ម្ដាយរបស់ទារក ឈ្មោះអ្នកស្រី ម៉ារី នាក់ ស៊ីថា អាយុ ៣៥ ឆ្នាំ បានរៀបរាប់ឱ្យដឹងដែរថា គាត់មានអំណរសប្បាយយ៉ាងខ្លាំងដែលព្រះវិហារសន្តយ៉ូសែប អនុញ្ញាតអោយកូនអាយុ៧ខែរបស់គាត់ទទួលពិធីជ្រមុជទឹក។

អ្នកស្រីបន្ថែមថា៖«ស្វាមីរបស់គាត់មិនមែនជាគ្រីស្តបរិស័ទទេ ប៉ុន្តែគាត់បានឈ្វេងយល់ជំនឿខាងកាតូលិកយ៉ាងច្បាស់ និងរួមផ្សំជាមួយជំនឿរបស់គាត់ផងដែរ ដែលសុខចិត្ត បម្រើនឹងធ្វើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់»។

អ្នកស្រីបានបញ្ជាក់ទៀតថា៖«គាត់ស្រលាញ់ព្រះជាម្ចាស់ ដោយសារតែព្រះជាម្ចាស់ បានបូជាព្រះជន្មដើម្បីរំដោះបាបមនុស្សលោក។ គាត់បន្ថែមថា «ខ្ញុំចង់អោយកូនបាន រួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ដែលមានព្រះជន្មថ្មីដ៏រុងរឿង»។

អ្នកស្រី ស៊ីថា បន្តទៀតថា នៅថ្ងៃខាងមុខនាងនឹងអប់រំណែនាំ កូនអោយបានល្អបំផុត នឹងបង្រៀនអប់រំជំនឿអោយស្គាល់ពីព្រះយេស៊ូតាមដំណាក់កាលនីមួយៗ របស់សៀវភៅ ក៏ដូចជាបង្រៀនកូនតាមរយៈសកម្មភាពព្រះសហគមន៍ មានដូចជា កូនៗសាលាមត្តេយ្យ ក្រុមកុមារកាយឫទ្ធ ក្រុមជំទង់ ហើយរហូតដល់ពេលកូនធំពេញវ័យ។

ម្ដាយរបស់ទារកបានបន្ថែមទៀតថា៖«នាងខ្ញុំសង្ឃឹម ថាទៅថ្ងៃខាងមុខកូនរបស់នាងខ្ញុំពេលធំឡើងគាត់ នឹងក្លាយជាគ្រីស្តបរិស័ទមួយដែលដើរតាមគន្លងរបស់ ព្រះជាម្ចាស់យ៉ាងល្អប្រពៃ»។

សព្វថ្ងៃគ្រួសាររបស់អ្នកស្រីម៉ារី នាក់ ស៊ីថា រស់នៅក្នុងភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត៕

# លោកអភិបាល អូលីវីយេ ទទួលគោរមងារសាសនា

*អត្ថបទ៖ ដាលីស*

លោកអភិបាលព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ ទទួលគោរមងារពីថ្នាក់ដឹកនាំព្រះពុទ្ធសាសនា ជា "មហាឧបាសកពុទ្ធសាសនូបឧបត្ថម្ភក៏" នាព្រឹកថ្ងៃទី ៣០ មេសា ២០២២ នៅវត្តអង្គមន្ត្រី ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាព ព្រះអនុគណៈស្រុកត្រាំកក់ ឯកឧត្តម សេង សុមុន្នី រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា។











ព្រះតេជគុណ ង៉ែត ចំរើន ព្រះចៅអធិការវត្តអង្គមន្ត្រី មានថេរដីកាអំពីសម្មិទ្ធិផលនានា ដែលលោកអភិបាល ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ អូលីវីយេ បានប្រគេនដល់វត្តអង្គមន្ត្រីមាន៖ រូបសំណាកព្រះមុជ្ជលិន ព្រះអង្គប្រោសបញ្ចគីក្រមង៉ុយ ព្រះបាទជ័យវរ្ម័នទី៧ បន្ទប់ទឹក ចង្រ្កានបាយ សួនបន្លែ កញ្ចុះ ស្ពានស្រះទឹក ដែលមានទឹកប្រាក់សរុប ២២១៧ដុល្លារ និង១៧១ដុល្លារ ក្នុងសម័យព្រះចៅអធិការផ្ទាល់ និងមានប្រាក់ ១២០៧ដុល្លារទៀតកាលពីមុន។

ព្រះធម្ម ចយ ពៅ និមន្តប្រកាសពីព្រះរាជប្រកាសនីយប័ត្រ លេខ ០១៨, ២៧ រ.ប.ក គណៈមហានិកាយកម្ពុជា ចុះថ្ងៃទី ៤ មករា ២០២២ ដោយសម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារ ត្រាស់បង្គាប់សម្រេច៖ ផ្តល់នូវគោរមងារជូនលោកអភិបាល អូលីវីយេ ជាមហាឧបាសកពុទ្ធសាសនូឧបត្ថម្ភក៏។ ព្រះតេជគុណមានថេរដីកាថា ប្រកាសនីបត្រនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

លោកអូលីវីយេ ជំនួសហស្ថេអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ដែលត្រូវទទួលគោរមងារ មានប្រសាសន៍ទៅកាន់អង្គពិធីថា «ខ្ញុំគិតថាការជួបជុំគ្នាក្នុងព្រឹកនេះ មិនមែនត្រឹមតែដើម្បី មើលឃើញឋានៈជា មហាឧបាសក ដែលខ្ញុំព្រះករុណាបានទទួល តែជាពិសេសគឺដើម្បីឲ្យយើងជួបជុំគ្នានៅក្នុងផ្លូវថ្មី ដោយណែនាំឲ្យយើងដើរនៅក្នុងមាគ៌ានៃសុខសន្តិភាព ឲ្យយើងចេះបង្កើតទំនាក់ទំនងជាមួយគ្នា»

លោកបានបន្ថែមថា តាមរយៈការធ្វើសមាធិ និងការអធិដ្ឋាន ណែនាំឲ្យជីវិតរបស់យើងមិនត្រឹមតែភ្ជាប់ជាមួយលោកីយ៍ ភ្ជាប់ជាមួយនឹងបញ្ហាបច្ចុប្បន្ននេះ ដូចជា ឈ្លោះគ្នា ស្អប់គ្នា ប្រើអំពើហិង្សា ផ្ទុយទៅវិញ ជាពេលវេលាមួយដែលយើងចេញពីទុក្ខលំបាកនៅក្នុងពិភពលោក ដើម្បីទទួលពន្លឺថ្មី។

លោកអភិបាលអូលីវីយេ សង្កត់ធ្ងន់ថា កិច្ចសន្ទនាជាកត្តាសំខាន់ ដែលបង្កើតភាពជាបងប្អូន ដោយសារនៅទីនេះយើងជាបងប្អូនតែមួយ ជនជាតិខ្មែរ មានវប្បធម៌តែមួយ ភាសាតែមួយ មានចិត្តតែមួយដែលធ្វើដំណើរជាមួយគ្នា ទោះបីជាយើងមានសាសនាខុសខុសគ្នាក៏ដោយ។ យើងត្រូវយកចិត្តទុកដាក់ដើម្បីយល់ចិត្តគ្នាទៅវិញទៅមក ហើយនេះណែនាំឲ្យយើងបង្កើតពិភពថ្មីមួយ ដោយចេះសន្ទនារវាងគ្នា ដោយនឹកឃើញពិតមែន យើងជាបងប្អូនបង្កើតតាំងពីដើមរៀងមក។

លោកអភិបាលបញ្ជាក់ទៀតថា មនុស្សគ្រប់គ្នាអាចទទួលចំណេះដឹងពីគ្នាទៅវិញទៅមក ហើយក៏ត្រូវការការអប់រំផ្លូវចិត្តនិងវិញ្ញាណពីខាងសាសនាផងដែរ ដើម្បីឲ្យគេក្លាយជាមនុស្សពេញលក្ខណៈ។

លោកបន្ថែមថា សាសនាណែនាំឲ្យចូលទៅក្នុងតម្លៃនៃគុណធម៌ វប្បធម៌ និងសីលធម៌នៅក្នុងជីវិតរស់នៅ។ «បើសិនជាចិត្តរបស់យើងអាក្រក់ងងឹត ហើយវិញ្ញាណរបស់យើងរីងស្ងួត យើងធ្វើដូចម្តេចដើម្បីឱ្យពិភពពិតរបស់យើងមានយុត្តិធម៌ សេចក្តីសង្ឃឹមនិងសុខដុមរមនាកើតឡើង? ដូច្នេះការអប់រំដែលយើងបានទទួល គឺដើម្បីឲ្យក្លាយទៅជាមនុស្សពេញលក្ខណៈ តាមផ្លូវវិញ្ញាណ តាមផ្លូវចិត្ត និងតាមចំណេះដឹងដែរ»

> យើងដឹងថាសុខសន្តិភាពកើតឡើង គឺត្រូវកើតឡើងនៅក្នុងក្រុមគ្រួសាររបស់យើងសិន មិនមែននៅក្នុងពិភពលោកទូទៅនោះឡើយ ប៉ុន្តែបើ គ្រួសារមួយមានក្តីសុខ ភូមិមួយមានសេចក្តីសុខ ខេត្តមួយមានសេចក្តីសុខ ប្រទេសមានសេចក្តីសុខ ណែនាំឲ្យពិភពលោកមានសេចក្តីសុខផងដែរ

ជាមួយគ្នានោះដែរ អភិបាលព្រះសហគមន៍បានទាញចំណាប់អារម្មណ៍អំពី ភាតរភាព និងមិត្តភាព។ លោកបានរំលឹកថា ថ្ងៃនេះកើតឡើងដោយសារតែយើងបានខិតខំធ្វើពីមួយថ្ងៃទៅមួយថ្ងៃ តាំងតែពីឆ្នាំ២០០២មកម្ល៉េះ ដែលចាប់ផ្តើមដោយ «ខ្ញុំបានជូនគីកៅអីទេសនា ប្រគេនដល់ចៅអធិការទីមួយនៃវត្តអង្គមន្ត្រី ហើយពីពេលនោះយើងចាប់ផ្តើមមានទំនាក់ទំនងជាមួយគ្នាពិតមែន។ នៅពេលបុណ្យភ្ជុំបិណ្ឌឬចូលឆ្នាំខ្មែរ ខ្ញុំព្រះករុណាតែងតែមកវត្តដើម្បីជួបជុំ ជាមួយព្រះសង្ឃ និងជូនពរ ហើយនៅពេលបុណ្យព្រះយេស៊ូប្រសូត ព្រះចៅអធិការវត្ត ជាមួយគណៈកម្មការបាននិមន្តដល់ព្រះវិហាររបស់យើងនឹងជូនពរផង ជូនអង្ករផង មានដូង មាននំ ដើម្បីជួយដល់អ្នកក្រីក្រក្នុងឱកាសនៃបុណ្យណូអែល»

លោកអភិបាលបានបញ្ជាក់ថា ពីមួយថ្ងៃទៅមួយថ្ងៃ យើងបានបង្កើតមិត្តភាពពិតប្រាកដ ដោយរួមទាំងសកម្មភាពផងដែរ។ ជាក់ស្តែងក្នុងកូវីដ-១៩ យើងរួមជាមួយគ្នាព្រះចៅអធិការនិងខ្ញុំព្រះករុណាបានទៅមណ្ឌលចត្តាឡីស័ក និងជាច្រើនដងរួមជាមួយឥស្លាមសាសនា ពុទ្ធសាសនា និងគ្រីស្តសាសនា ទៅសួរសុខទុក្ខបងប្អូនដែលកំពុងឃុំឃាំងនៅក្នុងខេត្តកំពត ព្រះសីហនុ និងតាកែវ ដោយផ្តល់អំណោយ និងសូត្រធម៌អធិដ្ឋានឲ្យគេមានកម្លាំងកាយ និងកម្លាំងចិត្ត។ យើងរួមគ្នាដើម្បីសួរសុខទុក្ខអ្នកជំងឺ ហើយបានរៀបចំវីដេអូដើម្បីបង្ហាញអំពីសុខសន្តិភាពពិតប្រាកដជាក់ស្តែង។ យើងបានធ្វើសកម្មភាពអន្តរសាសនាជាច្រើនដង ក្នុងខេត្តតាកែវ ជាមួយអ្នកជំងឺអេដស៍និងអ្នកផ្ទុកមេរោគអេដស៍ ដើម្បីបង្ហាញអំពីភាតរភាព មិនមែនត្រឹមតែនិយាយ អំពីសេចក្តីស្រឡាញ់ និងការគោរពគ្នា ប៉ុន្តែយើងមានស្នាដៃរួមជាមួយគ្នា។

ព្រះមង្គល សៅដារ៉ាវី ព្រះអនុគណៈស្រុកត្រាំកក់ មានសង្ឃដីកាថា ការដឹកនាំក្នុងការងារសាសនាក្នុងស្រុកត្រាំកក់ ជាពិសេសវត្តអង្គមន្ត្រី «អាត្មាឃើញ

*បន្តទៅទំព័រ-១៩*

# ព្រះវិហារសន្តយ៉ូហានបាទីស្តនៅប៉ូស្រាសម្ពោធជាផ្លូវការ







*ដោយកែវ កញ្ញា*

បូពណ៌ក្រហម ដែលមានស្ត្រីពីរនាក់កាន់យ៉ាងស្រស់ស្អាត រង់ចាំប្រធានកិត្តិយសមកកាត់ផ្តាច់ ដើម្បីបើកឲ្យមនុស្សដែលរង់ចាំចូលទៅខាងក្នុង អមដោយចម្រៀង ច្រៀងលើកតម្កើងព្រះជាម្ចាស់យ៉ាងរងំ លាន់ឮចេញពីខាងក្នុង ហាក់ដូចជាអន្ទះសារចង់ចួបជាមួយអ្នកនៅខាងក្រៅ។

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានឡើងមកផ្តាច់ខ្សែបូ ហើយលោកបូជាចារ្យ ហ្វ្រង់ស្វ័រ អេមេល្យដាល បានទទួលសោរពីលោក រួចបើកចំហទ្វារព្រះវិហារ ឲ្យមនុស្សជាច្រើនរយនាក់បានចូល។

នេះជាព្រះវិហារថ្មីមួយ សម្រាប់គ្រីស្តបរិស័ទខ្មែរភាគតិចដើមកំណើតពូនង រស់នៅក្នុងឃុំប៉ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ ព្រះវិហារនេះមានឈ្មោះថា សន្តយ៉ូហានបាទីស្ត ត្រូវបានដាក់សម្ពោធកាលពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ ។

ក្នុងធម្មទេសនានាថ្ងៃនោះ លោកអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម មានប្រសាសន៍ថា តាមពិតព្រះយេស៊ូមានគម្រោងការរបស់ព្រះអង្គ ហើយទ្រង់បានរៀបចំរួចហើយសម្រាប់យើង ច្រើនដងយើងអត់យល់ ប៉ុន្តែព្រះអង្គរៀបចំហើយ ដូចអត្ថបទគម្ពីរថ្ងៃនេះ (យហ២១,១-១៩)។

លោកអភិបាលបានបន្ថែមថា នៅពេលយើងខ្សោយ ទោះបីជាយ៉ាងណា យើងធ្វើឲ្យអស់ពីសមត្ថភាព ទោះបីជាយ៉ាងណាព្រះយេស៊ូយល់អំពីសមត្ថភាពរបស់យើង។ នៅថ្ងៃនេះនៅពេលដែលយើងនៅទីនេះ យើងអធិដ្ឋានជាមួយគ្នានៅក្នុងព្រះវិហារថ្មីនេះ អង្វរព្រះជាម្ចាស់ សម្រាប់ព្រះដំណាក់របស់ព្រះអង្គ សម្រាប់កន្លែងថ្មីនេះដ៏ស្អាត និងជាកន្លែងថ្មី ជាកន្លែងដែលនឹងជួយយើងឲ្យយើងយល់កាន់តែច្បាស់ អំពីសមត្ថភាពរបស់យើងដែលធ្វើសម្រាប់ព្រះជាម្ចាស់។

លោកប្រ៊ុយណូ បានលើកទឹកចិត្តដល់គ្រីស្តបរិស័ទទៀតថា៖ «យើងខ្សោយមែនតែយើងអធិដ្ឋាន យើងខ្សោយមែនតែយើងនៅជាមួយគ្នា យើងខ្សោយមែនក៏នៅតែបង្កប់សក្ខីភាពនៃជំនឿរបស់យើង។ សូមព្រះជាម្ចាស់បន្តណែនាំយើង ពង្រឹងជំនឿរបស់យើង ប្រទានកម្លាំងកាយកម្លាំងចិត្តឲ្យយើងម្នាក់»

ក្នុងវ័យជា៧៥ឆ្នាំ ជាជនជាតិដើមភាគតិចដែលបានចាប់ផ្តើមព្រះសហគមន៍នៅទីនេះ ជាមួយគ្រួសារចំនួន៩ទៀតបាន លោកព្រឹ ត្រេ បានឲ្យដឹងថា កាលពីមុនព្រះវិហារនេះតូចចង្អៀតពិបាកថ្វាយបង្គំ បន្ទាប់មកយើងក៏ស្នើសុំទៅលោកបូជាចារ្យ លោកអភិបាល ហើយពួកគាត់បានយល់ព្រមតាំងពីឆ្នាំ២០០០។ «ពេលនេះយើងមានព្រះវិហារហើយ យើងមានចិត្តសប្បាយ ដូចគោលបំណងរបស់ខ្ញុំនៅក្នុងចិត្តដើម្បីកូនចៅតទៅមុខទៀតឲ្យរីកចម្រើន ដើម្បីអាចថ្វាយបង្គំព្រះជាម្ចាស់ ហើយបង្ហាញជំនឿដល់បងប្អូនដទៃទៀត អំពីការរស់នៅការសាមគ្គីភាព ផ្តល់អាទិភាពឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យយើងអាចទៅមុខ»

ព្រឹទ្ធាចារ្យរូបនេះ បានឲ្យដឹងទៀតថា «ខ្ញុំសង្ឃឹមថា សង្ឃឹមថាថ្ងៃអនាគតព្រះសហគមន៍នឹងរីកចម្រើន»

លោកបានឲ្យដឹងថា កាលពីមុនមកព្រះវិហារនេះចាប់ផ្តើមដោយមានគ្រីស្តបរិស័ទ មិនដល់២០នាក់ទេ ដែលបានភៀសខ្លួនទៅកាន់ប្រទេសវៀតណាម នៅក្នុងពេលកម្ពុជាមានសង្គ្រាម ហើយបានជ្រកក្រោនជាមួយគ្រីស្តបរិស័ទកាតូលិកនៅប្រទេសវៀតណាម ក៏បានផ្លាស់ប្តូរជំនឿ។ លោកបន្ថែមថា «យើងជាបងប្អូនជនជាតិកាលនោះ យើងអត់មានអ្វីសែនព្រេន ហើយឃើញការរស់នៅរបស់បងប្អូនគ្រីស្តបរិស័ទល្អ មានការរាប់អាន ហើយ(ជំនឿនេះ)យើងអាចតាមគេបាន»

ព្រះសហគមន៍តំបន់មណ្ឌលគិរី ត្រូវបានបង្កើតឡើងក្រោយបញ្ចប់សង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជា ដែលមានគ្រីស្តបរិស័ទប្រមាណ១៥គ្រួសារដែលបានទទួលជឿក្នុងពេលភៀសខ្លួនទៅប្រទេសវៀតណាម ហើយបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញក្នុងថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៨៦ មកតាំងទីលំនៅដាក់ដាំចំនួន៥គ្រួសារ និង១០គ្រួសារនៅប៉ូស្រា។ ហើយរាល់ថ្ងៃអាទិត្យ ពួកគាត់តែងជួបជុំគ្នាក្រោមដើមឈើ ដើម្បីលើកតម្កើងព្រះជាម្ចាស់ និងចាប់ផ្តើមកសាងផ្ទះដើម្បីជួបជុំអធិដ្ឋាន។ ក្នុងអំឡុងពេល៩ឆ្នាំ ព្រះសហគមន៍នេះ រស់នៅដោយគ្មានបូជាចារ្យទទួលខុសត្រូវ។ ក្នុងឆ្នាំ១៩៩៦ ទើបមានសាសនទូត មកជាបន្តបន្ទាប់ រហូតដល់ពេលបច្ចុប្បន្ននេះ។

លោកប្រប ព្យច ប្រធានគណៈកម្មការនៃព្រះសហគមន៍ប៉ូស្រាបានឲ្យដឹងថា នៅក្នុងពេលបច្ចុប្បន្ននេះមានគ្រីស្តបរិស័ទចំនួនជាង២០០នាក់ ដែលមាន១២៤គ្រួសារ។

លោកបានឲ្យដឹងថា «សម្រាប់ខ្ញុំនិងបងប្អូននៅប៉ូស្រានេះដែលបានទទួលវិហារថ្មី គឺមានអំណរសប្បាយ ដោយសារពីមុនយើងអត់មានព្រះវិហារ យើងមានតែព្រះវិហារតូច ហើយគ្រីស្តបរិស័ទក៏កាន់តែកើនឡើងៗ ដោយគ្មានកន្លែងអង្គុយ កន្លែងចង្អៀត ប៉ុន្តែពេលនេះយើងមានព្រះវិហារធំ ដូច្នេះយើងអរគុណព្រះជាម្ចាស់ ដែលប្រទានឲ្យមានអ្នកជួយដើម្បីធ្វើព្រះវិហារថ្មី»

លោកបានបន្ថែមទៀតថា «ខ្ញុំសង្ឃឹមថាព្រះវិហារថ្មីនេះ ឲ្យយើងមានជំនឿកាន់តែមាំឡើង ដើម្បីឲ្យយើងងាយស្រួលអប់រំជំនឿ បង្រៀនកូនក្មេង និងបន្តជំនឿពីម្នាក់ទៅម្នាក់ទៅដល់ម្នាក់ដែលមិនទាន់ស្គាល់ព្រះយេស៊ូ»

យុវតី ភារី បានឲ្យដឹងថា «សម្រាប់ខ្ញុំផ្ទាល់ នៅពេលដែលមានព្រះវិហារធំហើយថ្មីបែបនេះ គឺជាកន្លែងដែលឲ្យយើងអាចចូលរួមនិងរួមគ្នាចំពោះយុវជននិងគ្រិស្តបរិស័ទ ចូលរួមគ្នាបានយ៉ាងច្រើន លោកក៏នឹងមានកន្លែង និងមានកន្លែងសម្រាប់រៀនអប់រំជំនឿ សម្រាប់កុមារនិង ចាស់ៗ និងជាកន្លែងដែលយើងអាចជួបគ្នានៅក្នុងអង្គព្រះគ្រីស្ត។ »

លោកបូជាចារ្យ ហ្វ្រង់ស្វ័រ អេមេល្យដាល ជាបូជាចារ្យទទួលខុសត្រូវព្រះវិហារនេះ បានមានប្រសាសន៍ថា «ខ្ញុំធ្លាប់ប្រៀនប្រដៅគ្រីស្តបរិស័ទថា អ្វីដែលសំខាន់គឺការសាងសង់ព្រះសហគមន៍ គឺគ្រីស្តបរិស័ទម្នាក់ៗគឺជាថ្មដា ជាអគារផ្ទាល់ខ្លួន ព្រះវិហារខ្ញុំធ្លាប់ប្រាប់ថាមិនសូវសំខាន់ ប៉ុន្តែតាមពិត ថ្ងៃនេះបង្ហាញថា ព្រះវិហារសំខាន់ណាស់គឺជាទីសម្គាល់សម្រាប់អ្នកភូមិអ្នកដទៃ ថាមានអ្នកជឿពិតប្រាកដមែន»

លោកបូជាចារ្យបន្តថា ជាពិសេសនៅប៉ូស្រា នៅទីនេះ យើងមានព្រះវិហារធំ បង្ហាញអំពីជំនឿដែលបានរីកចម្រើនលូតលាស់របស់គ្រីស្តបរិស័ទ តាំងតែពីយូរឆ្នាំមកហើយ។ ក្នុងព្រះវិហារមានព្រះកាយព្រះគ្រីស្ត ព្រះពន្លា អាសនៈ ជាទីសម្គាល់នៃវត្តមានរបស់ព្រះជាម្ចាស់ដែលស្រឡាញ់មនុស្សទាំងអស់។

លោកហ្វ្រង់ស្វ័រឲ្យដឹងថា នៅទីនេះ មានមនុស្សជាច្រើនផ្លាស់ប្តូរជំនឿចូលក្នុងគ្រីស្តសាសនា ងាយស្រួលជាងបងប្អូនខ្មែរ ដោយសារបងប្អូនខ្មែរជាពុទ្ធបរិស័ទមិនសូវជំរុញឲ្យចូលទៅក្នុងគ្រីស្តសាសនា។ នៅទីនេះស្រួលម្យ៉ាងក៏ប៉ុន្តែខ្ញុំគិតថា ជនជាតិដើមភាគតិចពូនង ត្រូវការការរីកចម្រើននៅក្នុងជំនឿបន្ថែមទៀត ត្រូវឈ្វេងយល់អំពីជំនឿបន្ថែមទៀត ស្វែងរកព្រះជាម្ចាស់ ស្រលាញ់ព្រះជាម្ចាស់កាន់តែខ្លាំងឡើង។

លោកបន្តថា «ខ្ញុំគិតថាអគារនេះ នឹងជួយបងប្អូនជនជាតិពូនង យល់ដឹងខ្លួនអំពីតម្លៃនៃជំនឿ និងតម្លៃនៃការស្វែងរកព្រះជាម្ចាស់កាន់តែច្រើនទៅ»

លោកបានបញ្ជាក់ថា ព្រះវិហារនេះ សម្រាប់បងប្អូនជនជាតិពូនងទាំងអស់នៅឯមណ្ឌលគិរី ដូចជា ដាក់ដាំ កែវសីមា ដែលមានគ្រីស្តបរិស័ទកាតូលិក ហើយនិងសម្រាប់ភូមិភាគកំពង់ចាមទាំងមូល ពីព្រោះកំពង់ចាម មិនសូវមានព្រះវិហារធំប៉ុន្មានទេ «ខ្ញុំសង្ឃឹមថាអនាគតទៅព្រះវិហារនេះអាចធ្វើសន្និបាតប្រជុំ សម្រាប់បងប្អូនទាំងអស់គ្នា នៅក្នុងភូមិភាគ ហើយព្រះវិហារក៏មិនមែនជាកន្លែងដើម្បីគ្រាន់តែថ្វាយបង្គំ ដើម្បីធ្វើតែពិធីបុណ្យនិងពិធីជ្រមុជទឹក ឬអគ្គសញ្ញានានាទេ គឺជាកន្លែងដើម្បីប្រជុំកសាងក្រុមគ្រួសារ តែមួយគឺព្រះសហគមន៍»

ព្រះវិហារសន្តយ៉ូហានបាទីស្ត(ប៉ូស្រា) ត្រូវបានកសាងឡើងក្នុងឆ្នាំ២០២១ ដោយមានជំនួយឧបត្ថម្ភពីព្រះសហគមន៍ក្នុងស្រុកនិងក្រៅស្រុក។ ព្រះសហគមន៍នេះ មានយុវនារីមួយរូបថ្វាយខ្លួនជាអ្នកបួស និងកំពុងមានលោកបូជាចារ្យរូបទៀត ដែលនឹងត្រូវតែងតាំងក្នុងពេលឆាប់ៗនេះ៕

# បងប្រុស វី សំណាង ៖ «ខ្ញុំថ្វាយខ្លួនជាអ្នកបួស ដើម្បីបម្រើបងប្អូន»

*អត្ថបទ៖ ឆាក លាំង*




បច្ចុប្បន្នជាសិស្សទេវវិទ្យាល័យឆ្នាំទី៧ និងជាឆ្នាំចុងក្រោយ លោក យូហានបាទីស វី សំណាង មានបំណងប្រាថ្នាធ្វើជាបូជាចារ្យតាំងពីតូចមក នៅពេលដែលលោកបានចូលក្នុងព្រះវិហារមកម្ល៉េះ ដោយសារលោកឃើញលោកបូចារ្យ ពាក់អាវសស្អាតៗ លោកចង់ពាក់អាវនោះដែរ។

បងប្រុស វី សំណាង ជាកូនប្រុសនៃគ្រួសារគ្រីស្តបរិស័ទមួយ ដែលមានបងប្អូនប្រុសចំនួនពីរនាក់ រស់នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

បងប្រុសបានដឹងថាព្រះវិញ្ញាណព្រះជាម្ចាស់បានបំភ្លឺលោកឲ្យចាប់អារម្មណ៍ជីវិតអ្នកបួសតាមរយៈការស្រលាញ់សម្លៀកបំពាក់លោកបូជាចារ្យតាំងពីកុមារភាព។

បងប្រុស វី សំណាង បានប្រាប់ថា ៖ «អាយុប្រហែលជាង១០ឆ្នាំ ក្នុងអំឡុងឆ្នាំ២០១៧ ខ្ញុំបានទៅព្រះវិហារជាមួយឪពុកម្តាយ ខ្ញុំឃើញលោកបូជាចារ្យស្លៀកសម្លៀកបំពាក់អាវសស្អាតណាស់ តាំងពីពេលនោះមកខ្ញុំមានចិត្តចង់ធ្វើជាបូជាចារ្យ»។

សិស្សទេវវិទ្យាល័យរូបនេះបានបន្តទៀតថា រហូតដល់វ័យចម្រើនឡើង ខ្ញុំក៏បានមកបន្តការសិក្សានៅសាលាដុនបូស្កូសំរោងអណ្តែត រយៈពេល៦ឆ្នាំ។ ដោយចិត្តស្រលាញ់និងមានការជួយជ្រោមជ្រែងពីលោកបូជាចារ្យនៅទីនោះ «ក្រោយរៀនចប់ទី១២ ខ្ញុំក៏សម្រេចចិត្តចូលសិក្សាទេវវិទ្យាល័យ ដើម្បីស្វែងយល់ជីវិតជាអ្នកបួសឲ្យកាន់តែស៊ីជម្រៅ ថាគួរជ្រើសជីវិតជាបូជាចារ្យភូមិភាគ ឬបូជាចារ្យបព្វជិត»។

ការរៀននៅទេវវិទ្យាល័យ បានផ្តល់ពេលវេលាច្រើនដល់រូបលោក ដើម្បីសិក្សាឈ្វេងយល់ពីជីវិតរបស់ព្រះយេស៊ូ រៀនតាមព្រះអង្គ បង្កើតទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយព្រះយេស៊ូតាមរយៈការអធិដ្ឋាន និងកម្មវិធីអភិបូជារាល់ថ្ងៃ។ ពេលវេលានេះបានផ្តល់ចម្លើយយ៉ាងច្បាស់ឲ្យបងប្រុស វី សំណាង ដឹងថាព្រះជាម្ចាស់ចង់ឲ្យលោកធ្វើអ្វី។

អង្គុយផ្តល់បទសម្ភាសន៍ដោយភាពរាក់ទាក់ជាមួយក្រុមការងារ វិទ្យុវេរីតាស អាស៊ី និស្សិតទេវវិទ្យាល័យរូបនេះបានបន្ថែមថា មនុស្សយើងម្នាក់ៗ មានការលំបាកផ្សេងៗគ្នា តែសំខាន់យើងត្រូវព្យាយាមរកដំណោះស្រាយ។

បងប្រុស វី សំណាង បានរៀបរាប់ឱ្យដឹងថា បទពិសោធជីវិតរស់នៅក្នុងទេវវិទ្យាល័យរយៈពេលជិត៧ឆ្នាំកន្លងមកនេះ លោកបានសិក្សាតាមកាវិភាគ និងគោលការណ៍របស់ទេវវិទ្យាល័យ រួមមា៤ចំនុចសំខាន់ៗគឺ ខាងផ្លូវវិញ្ញាណ ខាងបញ្ញាស្មារតី ខាងជីវិតបំរើព្រះសហគមន៍ និងការបណ្តុះបណ្តាលរបៀបរស់នៅជាមនុស្សដល់និស្សិតម្នាក់។ ក្នុងនោះដែរ លោកក៏បានជួបការលំបាកជាច្រើនក្នុងការសិក្សាដោយសារមិនបានរៀនពីមូលដ្ឋានគ្រឹះឆ្នាំ១ និងទី២ ដោយលោកបានចូលរៀនរួមជាមួយរៀមច្បងនៅឆ្នាំទី៣ រហូតដល់ឆ្នាំទី៧ ហើយលោកត្រូវបកទៅរៀនឆ្នាំទី១ និងទី២ដើម្បីបង្គ្រប់វិញ។

សិស្សទេវវិទ្យារូបនេះបានបន្តទៀតថា ផលលំបាកមួយវិញទៀតគឺភាសាបរទេសរបស់លោកនៅមានកំរិត ហើយឯកសារភាគច្រើនជាភាសាបរទេស និងបញ្ហាសាស្ត្រាចារ្យមិនគ្រប់គ្រាន់ផងដែរ។ បងប្រុសវី សំណាង បញ្ជាក់ថា ៖ «ការចែករំលែកពីរៀមច្បង បានជួយដោះស្រាយការលំបាកខ្ញុំច្រើនសម្រាប់មុខវិជ្ជាមួយចំនួន ការខិតខំជំនះឧបសគ្គ និងការព្យាយាមអធិដ្ឋានជាប្រចាំ ទើបធ្វើឲ្យការសិក្សានៅទេវវិទ្យាល័យរបស់ខ្ញុំមានផ្លែផ្កាមកដល់ថ្ងៃនេះ»។

លោកក៏បានប្រាប់ផងដែរថា ផលលំបាកមួយទៀតសម្រាប់លោក គឺការជំទាស់ពីក្រុមគ្រួសារមិនឲ្យខ្លួនចូលរៀនក្នុងក្រុមអ្នកបួស ព្រោះថាពេលនោះ ក្នុងគ្រួសារមានតែលោកម្នាក់ ជាកូន។ ហើយម្តាយមានបញ្ហាសុខភាព គ្រូពេទ្យប្រាប់ថាមិនអាចពពោះកូនក្រោយទៀតបានឡើយ។

លោកថា ៖ «ដោយសារព្រះវិញ្ញាណត្រាស់ហៅខ្ញុំនៅតែមានក្តីស្រមៃចង់ធ្វើជាអ្នកបួស ហើយបានខិតខំអធិដ្ឋានសុំឲ្យម្តាយខ្ញុំមានកូនម្នាក់ទៀត។ មិនយូរប៉ុន្មានព្រះជាម្ចាស់បានឆ្លើយតប ដោយគាត់មានកូនទី២ តែត្រូវឆ្លងកាត់ទុក្ខលំបាកជាច្រើនដោយបញ្ហាសុខភាព។ ក្រោយមកទៀតគ្រួសារខ្ញុំក៏អនុញ្ញាតឲ្យចូលឈ្វេងយល់ជាមួយក្រុមបួសរហូតមកទល់សព្វថ្ងៃនេះ»។

ឆ្នាំទី៧នេះ ជាឆ្នាំចុងក្រោយនៅទេវវិទ្យាល័យ ហើយបើមិនមានអ្វីប្រែប្រួល ក្រោយការវាយតំលៃពីសំណាក់លោកអភិបាលព្រះសហគមន៍ លោកនឹងទទួលការតែងតាំងជាបូជាចារ្យនាពេលអនាគតខាងមុខនេះ។

ជាមួយគ្នានេះ បងប្រុស វី សំណាង បានផ្ញើសារទៅយុវជន យុវនារីទាំងអស់ ជាពិសេសយុវជនថា មនុស្សម្នាក់ៗត្រូវក្លាហាន ចេះបើកភ្នែកបើកចិត្តទទួលយកទីសម្គាល់ណាមួយដែលព្រះជាម្ចាស់ត្រាស់ហៅ និងត្រូវហ៊ានឆ្លើយតាមការចង់បានរបស់ខ្លួនឯង ជាពិសេសការថ្វាយខ្លួនជាអ្នកបួសនាពេលអនាគត។

លោកបានប្រាប់ផងដែរថា ៖ «ជីវិតជាបូជាចារ្យកាតូលិក ពិតជាមានន័យណាស់សំរាប់រូបខ្ញុំផ្ទាល់ ព្រោះខ្ញុំចូលចិត្តកម្មវិធីអភិបូជា ចូលចិត្តអធិដ្ឋាន និងចូលចិត្តធ្វើកិច្ចមនុស្សធម៌ជាមួយបងប្អូនដែលជួបនឹងការលំបាក។ មិនត្រឹមតែប៉ុណ្ណោះ ជាបូជាចារ្យ បានណែនាំជំនឿឲ្យគ្រីស្តបរិស័ទគ្រប់រូបបានយល់ពីជំនឿ និងស្គាល់ព្រះជាម្ចាស់ពិតប្រាកដ»។

ទោះបីជាជួបនឹងការលំបាកក្នុងកាសិក្សានៅទេវវិទ្យាល័យយ៉ាងណាក៏ដោយ ក៏អនាគតបូជាចារ្យរូបនេះមិនដែលមានគំនិតចង់ចាកចេញពីទេវវិទ្យាល័យនោះទេ៕

*បន្តពីទំព័រ-១៧*

លោកអូលីវីយេ៉ជាក់ស្តែងបានជួយច្រើន និងអាត្មាយល់ថានេះជារឿងមួយល្អណាស់។ អាត្មាបានមកចូលរួមបុណ្យផ្កា អាត្មាឃើញថាទំនាក់ទំនងល្អ»

ឯកឧត្តម សេង សុមុន្នី រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ថ្លែងថា លោកមានការភ្ញាក់ផ្អើលនៅពេលបានឃើញលិខិតព្រះចៅអធិការវត្ត និងឆ្ងល់ថាហេតុអ្វីលោកអភិបាលអូលីវីយេ៉ជាសង្ឃរាជនៃគ្រីស្តសាសនាកាតូលិក តែអាចរួបរួមគ្នាជាមួយព្រះពុទ្ធសាសនាបាន?

លោកសុមុន្នី ថ្លែងបន្តថា ដូចសម្តេចហ៊ុនសែនបានប្រកាសថា "សុខដុមនីយកម្មសាសនាសំខាន់ណាស់ កុំឈ្លោះគ្នា កុំទាស់គ្នា"។ លោកអភិបាលគ្រីស្តសាសនាមិនប្រកាន់ទេ ហើយលោកអភិបាលក៏បានប្រគេនម៉ាស់ អាល់កុលថ្វាយសម្តេចសង្ឃព្រោះសុខដុមនីយកម្មសាសនាជារឿងសំខាន់។ ព្រះទាំងឡាយមានទិសដៅតែមួយគឺ "នាំសេចក្តីសុខដល់សត្វនិងមនុស្ស" ដូច្នេះសូមកុំប្រកាន់គ្នា។

ខណៈពេលនោះ លោកអភិបាលអូលីវីយេ៉ ក៏បានថ្លែងអំណរគុណ ចំពោះគោរមងារដែលបានទទួល មហាឧបាសកពុទ្ធសាសនូបឧបត្ថម្ភក៏។ លោកបានបន្ថែមថា «នេះមិនមែនតែសម្រាប់ខ្ញុំទេ ប៉ុន្តែនេះសម្រាប់ព្រះសហគមន៍កាតូលិក និងសម្រាប់សាសនាទាំងពីរដែលធ្វើការរួមជាមួយគ្នាធ្វើដំណើររួមជាមួយគ្នា»

លោកអភិបាលបានផ្តោតក្តីសង្ឃឹមយ៉ាងមាំលើទំនាក់ទំនងនេះ ដែលបន្តដើររួមគ្នាទៅមុខក្នុងរយៈពេលយូរឆ្នាំបន្តទៀតទោះស្ថិតនៅក្នុងការលំបាក ព្រោះក្តីសង្ឃឹមនឹងមាន ដោយដឹងថា សេចក្តីសុខសាន្តយើងអាចបង្កើតបាន ដើម្បីឲ្យពិភពលោកផ្លាស់ប្តូរបន្តិចម្តងៗទៅរកសន្តិភាព។ លោកបានសង្កត់ធ្ងន់ថា «ដោយយើងដឹងថាសុខសន្តិភាពកើតឡើង គឺត្រូវកើតឡើងនៅក្នុងក្រុមគ្រួសាររបស់យើងសិន មិនមែននៅក្នុងពិភពលោកទូទៅនោះឡើយ ប៉ុន្តែបើ គ្រួសារមួយមានក្តីសុខ ភូមិមួយមានសេចក្តីសុខខេត្តមួយមានសេចក្តីសុខ ប្រទេសមានសេចក្តីសុខ ណែនាំឲ្យពិភពលោកមានសេចក្តីសុខផងដែរ» ។

ការផ្តល់នេះ ជាកិត្តិយសសម្រាប់បូជាចារ្យជនជាតិបារាំងរូបនេះ ដែលទទួលនូវគោរមងារនេះ មិនដល់២ខែបន្ទាប់ពីលោកបានទទួលមេដាយកិត្តិយសជាតិសម្រាប់ការខិតខំប្រឹងប្រែងអស់ជាច្រើនទសវត្សរ៍របស់គាត់ក្នុងការអភិវឌ្ឍន៍សង្គម កាលពីថ្ងៃទី ០៨ ខែមីនា កន្លងទៅនេះ។

សាសនាកាតូលិកនៅកម្ពុជា មានអាយុកាលតាំងពីសតវត្សទី ១៦ ដោយសារការមកដល់របស់បុព្វជិតជនជាតិព័រទុយហ្គាល់ ឈ្មោះ Gaspar da Cruz ក្នុងឆ្នាំ ១៥៥៥។

ទោះបីជាមានការខិតខំប្រឹងប្រែងរបស់អ្នកផ្សព្វផ្សាយសាសនា និងអាណានិគមបារាំងនៅកម្ពុជាក្នុងសតវត្សទី ១៩ ក៏ដោយ ក៏សាសនាគ្រីស្តមិនអាចក្លាយជាកម្លាំងដ៏ខ្លាំងមួយនៅក្នុងប្រទេសដែលភាគច្រើនជាអ្នកកាន់សាសនាព្រះពុទ្ធនោះទេ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ បុរីវាទីកង់បានប៉ាន់ប្រមាណថា អ្នកកាន់សាសនាកាតូលិក នៅក្នុងប្រទេសកម្ពុជាមានចំនួនប្រហែលជា ១២០ ០០០ នាក់ ហើយប្រហែលជា ៥០ ០០០ នាក់ ជាជនជាតិវៀតណាម។

សាសនាកាតូលិកស្ទើរតែបានស្លាប់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ និងរបបខ្មែរក្រហមប្រល័យពូជសាសន៍ ដែលបានបណ្តាលឲ្យមនុស្សយ៉ាងហោចណាស់ ២ លាននាក់បានស្លាប់។ អ្នកផ្សព្វផ្សាយសាសនាជាច្រើនបានវិលត្រលប់មកវិញបន្ទាប់ពីការបញ្ចប់នៃសង្គ្រាមស៊ីវិលក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ហើយព្រះវិហារ ក៏បានបានកើតជាថ្មីម្តងទៀត។ សព្វថ្ងៃនេះ គ្រីស្តបរិស័ទមានតិចជាងមួយភាគរយនៃប្រជាជនប្រមាណ ១៧ លាននាក់ នៅកម្ពុជា៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ













## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម









## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង










